# ខ្មែរប៉ុស្តិ៍
ឆ្នេរខាងកើត
THE KHMER POST
EAST COAST
The Cambodian-American Biweekly News


Email : Khmerpostusa@gmail.com
Call : (267) 253-3947


VOLUME 04 ISSUE 61 June 11th - 24th 2010


# ហ៊ីបហុបខ្មែរហ្វីឡាដែលហ្វៀ

**ហ្វីឡាដែលហ្វៀ :** "ក្មេងៗឥឡូវវាចូលចិត្តចម្រៀងអិត្មានទំនុកជាបទ...ហើយវានាំគ្នាពិរោះទៅកើត... និយាយដូចអាខ្មៅ ស្តាប់ក៏មិនយល់..." នេះជាភាពពោលរបស់ចាស់ៗខ្មែរចំពោះសិល្បៈថ្មីនៃចំណូលចិត្តយុវជនជំទង់សម័យថ្មី ។ ហ៊ីបហុប

(តទៅទំព័រទី ០៥)



ហ៊ីបហុប នៅ "មន្ទីរសិល្បៈខ្មែរ"

# អណ្តូងរ៉ែមាសនៅកម្ពុជា



**ដកស្រង់ព័ត៌មានដោយ : ពិន សំខុន**

•••ប្រទេសកម្ពុជាធ្លាប់មានឈ្មោះថា "សុវណ្ណភូមិ" បានត្រូវគេកំណត់ថា ជាការពិតកាលពីថ្ងៃពុធ ទី២ ខែមិថុនា ២០១០ នាសប្តាហ៍មុននេះ ។ អណ្តូងមាសដ៏ធំបង្អស់ក្នុងពិភពលោកបានត្រូវគេរកឃើញនៅខេត្តរតនគីរី ខាងជើងឈាងខាងកើតនៃប្រទេសកម្ពុជា ក្នុងទំហំ ៨.១ លានតោន នៃរ៉ែមាស ដែលមាននៅស្រទាប់ធរណីនេះជាសេចក្តីប្រកាសរបស់ក្រុមហ៊ុនរ៉ែ OZ នៃប្រទេសអូស្ត្រាលី មកស្រាវជ្រាវនៅកម្ពុជានេះ ហើយបញ្ជាក់បន្ថែមដោយលោក សុខ ឡេង ប្រធាននាយកដ្ឋានអណ្តូងរ៉ែ នៃក្រសួងឧស្សាហកម្មនៅកម្ពុជា នៅក្នុងសន្និសីទនៃក្រសួងឧស្សាហកម្មជាមួយនឹងកម្មវិធីអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ នាសប្តាហ៍កន្លងទៅនេះ ។

ទំហំដ៏ធំធេងនៃរ៉ែមាសនៅកម្ពុជានេះ បើប្រៀបធៀបទៅនឹងរ៉ែមាសដែលមានមកហើយនៅក្នុងលោកនេះ (១៦១.០០០តោន) គឺទំហំធំជាង៥០ដងហើយនៅឆ្នាំ ២០០៨ ពិភពលោកផលិតបានមាស ២,២៦០តោនប៉ុណ្ណោះ - បើប្រៀបធៀបនឹងចំនួននោះកម្ពុជានឹងអាចផលិតបានបីពាន់ប្រាំរយឆ្នាំ (៣៥០០) ទើបយកមាសនេះអស់ពីអណ្តូងរ៉ែ ។

បើគិតជាចំនួនប្រាក់វិញ ក្នុងតម្លៃមាសសព្វថ្ងៃនេះកម្ពុជានឹងមានទើបទុនថ្មីចំនួន $៣០០ ទ្រីលីយ៉ុង (០ ដប់ពីដង) ភ្លាមនៅពេលដែលការស្រាវជ្រាវនោះ បានត្រូវកំណត់ជាផ្លូវការណ៍ចប់សព្វគ្រប់ ។ ចំនួនប្រាក់នេះនឹងផ្តល់ចំណាត់ថ្នាក់ដល់កម្ពុជា ថាជាប្រទេសដែលមានសម្បត្តិធំជាងគេបង្អស់ក្នុងលោក ដោយប្រៀបធៀបជាមួយសហរដ្ឋអាមេរិកផងដែរ ។ (តទៅទំព័រ ទី១៩ )

# និស្សិតដែលគេស្តាយនៅពេលបាត់បង់




**ខ្មែរប៉ុស្តិ៍, ហ្វីឡាដែលហ្វៀ :** មនុស្សប្រមាណជា ២០០នាក់ បាននាំគ្នាមកឈរដុតទៀនរំលឹកដល់វិញ្ញាណក្ខន្ធនិស្សិត ម៉ាឌីណា សេម អាយុ ១៨ឆ្នាំ រៀននៅវិទ្យាល័យ ហ្វែល នៅមួយថ្ងៃបន្ទាប់ពីគ្រោះថ្នាក់ដល់ជីវិត នាជ្រុងផ្លូវឡូគ្នាន់ និងលេខ២ ខាងជើងកាលពីថ្ងៃពុធ ទី១៩ ឧសភាកន្លងទៅនេះ ។

ម៉ាឌីណា គឺជានិស្សិតរូបស្រស់ស្អាត រាក់ទាក់ រៀនពូកែនៅថ្នាក់បញ្ចប់ បានបង្ហើយការងារដែលគ្រូដាក់ឱ្យធ្វើ "ព្យាបាលដោយសិល្បៈ"នៅពេលត្រឡប់មកផ្ទះវិញ នៅរសៀលថ្ងៃអង្គារនោះ នាងចុះពីរថយន្តសាលា ដើរទៅចិញ្ចើមថ្នល់នាជ្រុងផ្លូវនោះ ស្រាប់តែមានរថយន្តតូចមួយទៀត បានខ្ទាតពីគ្រោះថ្នាក់មួយ នាផ្លូវខ្វែងនោះ ឡើងចិញ្ចើមថ្នល់មកបុករូបនាងផ្ទប់ទៅនឹងជញ្ជាំងផ្ទះ បណ្តាលឱ្យបាក់ឆ្អឹងឆ្អែងជាច្រើនកន្លែង ។ រាត្រីម៉ោង ១០យប់ក្រុមគ្រួសារបានទទួលដំណឹងពីវេជ្ជបណ្ឌិតដែលបានសាកល្បងសង្គ្រោះជីវិតនាងថា "ម៉ាឌីណា បានស្លាប់ហើយ" ដំណឹងដ៏គួរឱ្យរន្ធត់នេះ បានក្លាយទៅជាទុក្ខដ៏ក្រៀមក្រំនៃគ្រួសាររបស់ ម៉ាឌីណា ដែលមានកូនស្រី ៩នាក់ រស់នៅផ្លូវ ហ្វីលីពខាងជើង ក្នុងគ្រួសារដែលបែកបាក់ ហើយឪពុកបានត្រឡប់ទៅរស់នៅឯកម្ពុជាវិញ ។ ហើយនេះក៏ជាទុក្ខដ៏ក្រៀមក្រំរបស់វិទ្យាល័យ ហ្វែល ដែលនៅទីនោះ ម៉ាឌីណា បានក្លាយទៅជាគំរូនៃនិស្សិតដែលខិតខំរៀនសូត្រជា

(តទៅទំព័រទី១៦)

## មាតិកាអត្ថបទ

| មាតិការឿង | ទំព័រ |
| --- | --- |
| ១- លទ្ធផលនៃការបោះឆ្នោត និង បាលី = រមណីយដ្ឋានល្បីល្បាញ | ទំព័រទី០២ |
| ២- សម រង្ស៊ី ចោទគណបក្សប្រជាជន | ទំព័រទី០៣ |
| ៣- ពីក្រុងមេកិន MACON រដ្ឋចរ័ជា និងមានអ្វីប្លែកនៅហ្វីឡាដែលហ្វៀ | ទំព័រទី០៤ |
| ៤- ប្រវត្តិព្រះអាចារ្យ ហែម ចៀវ | ទំព័រទី០៥ |
| ៥- ក្តីស្នេហ៍គ្មានទីបញ្ចប់ និងទឹកតែពាំពែង | ទំព័រទី០៦ |
| ៦- The Cambodia Daily | ទំព័រទី០៨-១៣ |




នាទីយល់ដឹងពីនយោបាយ :

# លទ្ធផលនៃការបោះឆ្នោតនៅផែនស៊ីវេនា កាលពីថ្ងៃទី១៨ ឧសភា ២០១០

**ដោយ : ពិន សំខុន**

នៅពេលដែលសេដ្ឋកិច្ចអាមេរិកាំង និងពិភពលោកបានធ្លាក់ចុះដិនដាប ការប្រកួតប្រជែងផ្នែកនយោបាយក៏មានកំរិតខ្ពស់ដូចគ្នា ពីព្រោះពលរដ្ឋចង់បានអ្នកដឹកនាំដែលពូកែគ្រប់គ្រងសម្បត្តិរដ្ឋ ហើយការពារដល់ប្រយោជន៍ពលរដ្ឋពិតប្រាកដ ។

ថ្ងៃទី១៨ ឧសភា ២០១០ ការបោះឆ្នោតជុំទី១ នៅរដ្ឋផែនស៊ីវេនានេះ បានបញ្ចេញលទ្ធផលគួរឱ្យភ្ញាក់ផ្អើលចំពោះបេក្ខជនព្រឹទ្ធសមាជិក ហេ្យា សេស្តាក់ អតីតឧត្តមនាវី ដែលបានឈ្នះ ៥៤% ទល់នឹង ៤៦% ប្រឈមមុខនឹង អាឡិន ស្ប៊ិចទ័រ ដែលគាំទ្រដោយប្រធានាធិបតី បារ៉ាក់ អូបាម៉ា ផង ដោយអភិបាលរដ្ឋផែនស៊ីវេនា អេដ រ៉ិនដល ផង និងដោយព្រឹទ្ធសមាជិក បុម ប្រាឌី ផង ។ លទ្ធផលរបៀបនេះបានន័យថា ពលរដ្ឋនៅផែនស៊ីវេនានេះមានការទទួលខុសត្រូវខ្ពស់លើវាសនារដ្ឋរបស់ខ្លួន មិនចេះតែដើរតាមអ្នកនយោបាយធំៗនោះទេ ។ ហេ្យា សេស្តាក់ បេក្ខជនគណបក្សប្រជាធិបតេយ្យ នឹងជួបប្រកួតជាមួយបេក្ខជន ផេត ធូមី នៃគណបក្សសាធារណរដ្ឋ ក្នុងតួនាទីព្រឹទ្ធសមាជិក ស.រ.អា ។

នៅមានលទ្ធផលនៃព្រឹទ្ធសមាជិកសម្រាប់រដ្ឋផែនស៊ីវេនា ដែលនៅពេលនៅ មានបេក្ខជន ៨រូប បានត្រូវប្តូរថ្មីរយៈពេលពីរឆ្នាំម្តង :

ចំណែកឯការបោះឆ្នោតតួនាទីអភិបាលរដ្ឋលោក អេដ រ៉ិនដល មិនអាចឈរឈ្មោះបានទៀតទេ ហើយអ្នកឈ្នះលើគេពីររូប គឺ ធម ត័របឹត នៃគណបក្សសាធារណរដ្ឋ នឹងជួបប្រកួត ផន អូណូរដូ នៃគណបក្សប្រជាធិបតេយ្យ នៅផ្តាច់ព្រាត់នាខែវិច្ឆិកាខាងមុខដែរ ។


អាឡិន ស្ប៊ិចទ័រ ហេ្យា សេស្តាក់

អ្នកវិភាគសង្កេតឃើញថា អ្នកបោះឆ្នោតបានបង្ហាញឆន្ទៈមិនចង់ឃើញការរើរុះការបង់តាក់ឱ្យរឹតតែច្រើន ដើម្បីទប់ទល់វិបត្តិសេដ្ឋកិច្ច... រីឯនិស្សិតជាច្រើនបានទៅបញ្ចេញឆន្ទៈទាក់ទងទៅនឹងសិក្សាធិការ ទោះជាថ្ងៃបោះឆ្នោតនោះសាលារៀនពុំបានបិទទ្វារសាលាសម្រាប់ឱ្យនិស្សិតទៅបោះឆ្នោតបាននោះទេ ៕







# បាលី : រមណីយដ្ឋានល្បីល្បាញជាងគេរបស់ ឥណ្ឌូនេស៊ី







•••បាលីត្រូវបានតាំងទីលំនៅដោយជនជាតិអូស្ត្រូណែណែស៊ី ប្រហែល 2000ឆ្នាំមុនគ.ស ដែលជាជនជាតិដើមរត់ចេញពីតៃវ៉ាន់ ឆ្លងកាត់តាមសមុទ្រអាស៊ីអាគ្នេយ៍ ។ វប្បធម៌ និងភាសារបស់ជនជាតិបាលីបានទាក់ទងយ៉ាងស្អិតរមួតជាមួយជនជាតិ ឬមនុស្សក្រុមកោះឥណ្ឌូនេស៊ី ហ្វីលីពីន និងអូសេអានី ។ ថ្មចម្លាក់បានចារទុកថ្ងៃខែតាំងពីពេលវេលានោះដែលត្រូវបានគេរកឃើញជិតភូមិសេគិត (Cekik) នៅភាគខាងលិចកោះ ។

វប្បធម៌ជនជាតិបាលីត្រូវបានទទួលឥទ្ធិពលយ៉ាងខ្លាំងពីជនជាតិ ឥណ្ឌា និងចិន ហើយជាពិសេសពីវប្បធម៌ហិណ្ឌូក្នុងដំណើរមួយដែលចាប់ផ្តើមនៅប្រហែលសតវត្សទី1នៃគ្រឹស្តករាជ ។ ឈ្មោះ បាលី (Bali) ឌ្វីប៉ា (Dwipa) ដែលមានន័យថា "កោះបាលី" ត្រូវបានរកឃើញពីអក្សរចារឹកខុសៗគ្នា ។ គឺក្នុងអំឡុងពេលនេះ ដែលប្រព័ន្ធធារាសាស្ត្រចាក់ស្រែះត្រូវបានបង្កើតឡើងដើម្បីដាំដុះដំណាំស្រូវ ។ សាសនា និងប្រពៃណីវប្បធម៌ ដែលនៅតែមានរហូតដល់ពេលនេះអាចឱ្យគេដឹងអំពីជីវភាពប្រជាជនសម័យនោះ ។

ចក្រភពម៉ាចាផាហ៊ុតហិណ្ឌូ (Hindu Majapahit Empine) ពីឆ្នាំ 1293 ដល់ឆ្នាំ 1520 នៃគ្រិស្តសករាជនៅកោះចាវ៉ាភាគខាងកើតបានបង្កើតអាណានិគមនិយមបាលីក្នុងឆ្នាំ 1343 ។ នៅពេលចក្រភពបានធ្លាក់ចុះមានការហូរចេញក្រុមបញ្ញវន្ត សិល្បករ បុព្វជិត និងតន្ត្រីករបីចាវ៉ាមករស់នៅបាលីក្នុងសតវត្សទី15 ។

បាលី ជាកោះឥណ្ឌូនេស៊ី ស្ថិតនៅចន្លោះកោះចាវ៉ា និងឡូមបុត។ កោះនោះជាខេត្តទី33នៃប្រទេស ហើយមានប្រជាជនរនៅ3.151.000ក្នុងឆ្នាំ 2005 វាជាគោលដៅទេសចរណ៍ដ៏ធំមួយក្នុងប្រទេសឥណ្ឌូនេស៊ី ហើយជាកន្លែងល្បីល្បាញខាងសិល្បៈរួមមាន របាំ ចម្លាក់ គំនូរ សិប្បកម្មស្បែក និងដែក ហើយនិងតន្ត្រី ។ ចំពោះសីតុណ្ហភាពវាជាតំបន់ត្រូពិចដែលមានរដូវពីរខុសគ្នា គឺរដូវប្រាំង ពីខែមេសា ដល់ខែតុលា និងរដូវវស្សាពីខែវិច្ឆិកាដល់ខែមីនា ។ សីតុណ្ហភាពជាមធ្យមមានកម្រិត30អង្សារពេញមួយឆ្នាំ ។ បាលីធ្លាប់បានជាផ្លូវដំណើរសម្រាប់ទេសចរចាប់តាំងពីទសវត្សឆ្នាំ 1970 និងរួមបញ្ចូលជាមួយវប្បធម៌សម្បូរបែប រួមជាមួយសមុទ្រពណ៌ផ្ទៃមេឃឆ្នេរខ្សាច់ដ៏ប្រណីត និងតំបន់ទេសចរណ៍ផ្សេងៗទៀត ។ កោះបាលី ជាហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ដ៏អស្ចារ្យមួយ ជាមួយរមណីយដ្ឋានធំៗ សណ្ឋាគារ និងភោជនីយដ្ឋានខ្នាតអន្តរជាតិ និងតំបន់ទេសចរណ៍ប្រកបដោយគុណភាព ។ មិនតែប៉ុណ្ណោះវាថែមទាំងផ្តល់ឱកាសដើម្បីចាកចេញពីឆ្នេរខ្សាច់ ហើយចូលខាងក្នុង ដែល

(តទៅទំព័រទី០៤)

# ប្រវត្តិព្រះអាចារ្យ "ហែម ចៀវ"

(តមកពីលេខមុន)



**ដោយ : អ៊ុម លឿម**

•••ស្រុកណា ភូមិណា ខេត្តណាក៏ចង់និមន្តលោកទៅសំដែងធម៌ទេសនាដែរ ម្លោះហើយលោកមានពេលទំនេរតិចតួចណាស់ ។

## សកម្មភាពដើម្បីសាសនា

លុះចប់កិច្ចសិក្សាហើយ លោកបានទៅធ្វើជាគ្រូបង្រៀនអក្សរសាស្ត្រជាតិ នៅវត្តក្រាំងដូង ដោយបង្រៀនព្រះសង្ឃ សម្រាប់ធ្វើគ្រូប្រកបដោយភាពជោគជ័យបំផុត ។ ក្រៅពីពេលបង្រៀន លោកឆ្លៀតសិក្សាខ្លួនឯងខ្លះទៀត ដើម្បីឈោងចាប់សេចក្តីពិតមកទុកខ្លួនឯង និងសិស្សានុសិស្ស ព្រមជាមួយនឹងឧបាសក ឧបាសិកាមួយអន្លើខ្លះទៀត ដែលត្រូវការចង់ចេះចង់ដឹង ។ នៅពេលលោកទេសនាមាត់ទទេលើកដំបូង មិនសូវមានអ្នកស្តាប់ច្រើនប៉ុន្មានទេ ព្រោះចាស់ជាន់ដើមទម្លាប់ទេសន៍តាមសាស្ត្រាស្លឹករឹត ។ ម្លោះហើយចាស់ៗខ្លះប្រកាន់ថា "ធម៌សម័យថ្មីគេមិនចេះស្តាប់ទេ" ។ ហេតុការណ៍ទាំងនេះ ពុំបានធ្វើឱ្យលោកគ្រូអាចារ្យ ហែម ចៀវ ព្រួយបារម្ភលំបាកចិត្តអ្វីទេ ដោយលោកឈ្លាសវៃក្នុងការពន្យល់មុនដំបូងតែងមានរឿងប្រតិកម្មដូច្នេះហើយ បើយើងមិនតស៊ូទេ មុខជាមិនបានសម្រេចបំណងឡើយ ។ ចាប់តាំងពីពេលនោះមកព្រះគ្រូអាចារ្យតែងធ្វើសេចក្តីស្និតស្នាលចំពោះចាស់ៗណាដែលមិនសូវចូលចិត្តស្តាប់លោកសំដែងធម៌មាត់ទទេ ។ មិនយូរប៉ុន្មានអ្នកទាំងនោះក៏ស្តាប់បានងាយយល់ ដោយថែមទាំងមានសម្លេងពិរោះផង ធ្វើឱ្យមានការស្រឡាញ់លោកហួសបរិយាយ ហើយចង់ឱ្យតែលោកអាចារ្យសំដែងធម៌ទេសនារាល់ថ្ងៃសីលបុណ្យទាន ។ នៅឆ្នាំនោះហើយដែលព្រះសង្ឃខ្មែរយើងចាប់ប្រែសូត្រមន្តពីភាសាបាលីមកជាភាសាខ្មែរ ។ ការប្រែឱ្យស្តាប់បាននេះ ធ្វើឱ្យអ្នកគិតមិនដល់ជេរត្មះតិះដៀលដល់ព្រះសង្ឃដែលខិតខំប្រែយ៉ាងសម្បើម រហូតដល់មានការប្តឹងផ្តល់ទៅតុលាការថែមទៀត ។ ប៉ុន្តែសេចក្តីតស៊ូប្រឹងប្រែងធ្វើការដើម្បីឱ្យសាសនារុងរឿង មានប្រយោជន៍ដល់មហាជន ដោយមិនតបតទៅតាមអំពើពាលល្ងង់ខ្លៅ ហើយកិច្ចការនោះក៏បានសម្រេចជោគជ័យ បានទទួលឋានៈជា "អាចារ្យសាលាបាលីជាន់ខ្ពស់" (សាស្ត្រាចារ្យ) មានកំរៃប្រចាំខែ៥០រៀល ល្មមនឹងទ្រទ្រង់ជីវភាពឱ្យសម្រេចទៅកើត ។

លោកគ្រូអាចារ្យ ហែម ចៀវ មានសាមណសក្តិជា "ព្រះបាឡាត់ឃ្លោសនាគ" របស់សម្តេចព្រះសង្ឃរាជ ជួនណាត ដោយពេលនោះលោកនៅជាព្រះពុទ្ធឃោសាចារ្យ ។ មុខងារថ្មីនេះ ពុំអាចទាញកម្លាំងចិត្តស្នេហាជាតិរបស់លោកឱ្យភ្លេចបានឡើយ ។ លោករឹងរឹតតែខំអានសៀវភៅខ្មែរ-បរទេសណាដែលសំខាន់ៗ ស្តីពីរឿងសាសនា នយោបាយ សេដ្ឋកិច្ច អក្សរសាស្ត្រ ទស្សនវិជ្ជាគ្រប់ទិវារាត្រី ឥតបីបណ្តោយឱ្យពេលវេលាកន្លងផុតដោយពុំបានធ្វើអ្វីជាប្រយោជន៍ទេ ។ ក្រៅពីការសិក្សាបង្រៀនសិស្ស ទេសនាពន្យល់ខ្មែរល្ងិតល្ងង់ ព្រះបាឡាត់ឃ្លោសនាគ ហែម ចៀវ ឆ្លៀតពេលទៅប្រាស្រ័យទាក់ទងនឹងវិរជនធំៗ ដែលមានគំនិតស្នេហាជាតិមាតុភូមិជាច្រើនទៀត ដូចជាលោក ប៉ាច ឈឿន, សឺង ង៉ុកថាញ់, ជុំ មួង, នួន ដួង និង សឹម វ៉ា ។ល។ ដើម្បីរកមធ្យោបាយរំដោះជាតិឱ្យរួចផុតពីខ្ញុំកញ្ជះរបស់បារាំងសេស ។ វេលាថ្ងៃមួយ លោក សឺង ង៉ុកថាញ់ បានទៅជួបព្រះបាឡាត់ ហែម ចៀវ ហើយប្រគេនដំណឹងថា : លោកគ្រូបាឡាត់បំណងយើងជិតបានសម្រេចហើយ ។ ពរ ! ជិតបានសម្រេចហើយលោក? ព្រះបាឡាត់ ហែម ចៀវ ចោទសួរសំនួរដោយងឿងឆ្ងល់ ។ លោក សឺង ង៉ុកថាញ់ ញញឹមបន្តិចរួចបន្លឺវាចាថា : ករុណាម្ចាស់សព្វថ្ងៃនេះ ដូច



លោកអាចារ្យដឹងស្រាប់ហើយ ទាហានជើងក្រហម និងជើងខ្មៅមិនត្រូវគ្នាទេ ដោយសារតែបារាំងចេះតែចាក់រុកឱ្យបែកសាមគ្គី ។ ឥឡូវនេះ បារាំងបានឱ្យខ្ញុំព្រះករុណា និមន្តព្រះសង្ឃឱ្យទេសនាពន្យល់ពួកទាហានទាំងនោះ ដើម្បីឱ្យកុំទាស់គ្នាទៀត ។ ក្នុងពេលនេះ ខ្ញុំករុណាសូមនិមន្តលោកអាចារ្យហើយ ។ យី ! ម៉េចក៏លោកមិននិមន្តលោកអាចារ្យ ប៉ាង ខាត់, សូ ហាយ ផង ។ ករុណា ខ្ញុំនិមន្តទាំងអស់អង្គហ្នឹង មិនឱ្យសល់ទេ តែធ្វើយ៉ាងណាកុំឱ្យពួកវាដឹង ឬសង្ស័យក្រែងទៅទេសនា ឬពន្យល់ទៀតមិនកើត ។ ពរ ! ប្រការនេះមិនថ្មីទេ ចំពោះរូបអាត្មាភាពព្រួយក្រែងខ្មែរយើងខ្លះចង់បានបុណ្យស័ក្តិពីបារាំង ហើយយកការណ៍ទៅឱ្យបារាំងវិញ !។ ករុណាវាពិតហើយ តែយើងមិនត្រូវខ្លាចទេ ។ យើងត្រូវខំពុះពារគ្រប់ឧបសគ្គ ទើបបំណងរបស់យើងបានសម្រេច ។ ពរ ! ត្រូវហើយលោក ! អាត្មាមិនដែលនឹកខ្លាចដល់គ្រោះថ្នាក់ផ្ទាល់ខ្លួនអ្វីទេ ។ តែគឺខ្លាចបែកការសម្ងាត់របស់ក្រុមបដិវត្តន៍យើង ! អាត្មាមិនមែនជាអ្នកនយោបាយដូចលោកទេ គឺជាអ្នកបួស គ្រាន់តែទេសនាពន្យល់ពុទ្ធបរិស័ទឱ្យស្គាល់ ឱ្យដឹង ឱ្យយល់ ឱ្យអនុវត្តន៍តាមគន្លងព្រះសម្ពុទ្ធទេតើ ! បើស្លាប់ដើម្បីជាតិ សាសនា អាត្មាក៏មិនតូចចិត្តដែរ ធ្វើម៉េចវាសនាមនុស្សវាត្រូវទទួលដូច្នេះ !។ ត្រូវហើយលោកគ្រូម្ចាស់ ! ការពិតដែលយើងត្រូវនិយាយនោះ យើងត្រូវនិយាយឱ្យប្រជារាស្ត្រដឹង ។ ខ្ញុំករុណាសុខចិត្តបូជាជីវិតជូនជាតិសាសនាអស់ហើយ ពុំមានខ្លាចស្លាប់ទេ ព្រោះយើងកើតមករមែងស្លាប់ទៅវិញជាធម្មតា ! ខ្ញុំករុណាគិតសុំថ្វាយបង្គំលាសិនហើយ ។ កុំប្រញាប់អញ្ជើញទៅលោកលោក !។ ខ្ញុំករុណាមានការច្រើនទៀតដែលត្រូវធ្វើ ! ចាំថ្ងៃក្រោយជជែកឱ្យយូរបន្តិច ។ ពរ! អញ្ជើញចុះលោក សូមឱ្យបានសុខ ! លោក សឺង ង៉ុកថាញ់ ក៏ក្រាបបង្គំលាព្រះអាចារ្យវិលទៅលំនៅស្ថានវិញ ប្រកបដោយទឹកមុខរីករាយជាអនេក ។

ក្រុមខ្មែរអ្នកភ្ញាក់រឭក ចេះតែដើរឃោសនាបញ្ចុះបញ្ចូលរាស្ត្រ ព្រះសង្ឃគ្រប់និគមជនបទឱ្យមានការឈឺចាប់ឡើង ។ លោក ប៉ាច ឈឿន មាននាមល្បីខ្ទរខ្ទាយ ដោយធ្វើជាចាងហ្វាងសារព័ត៌មាន "នគរវត្ត" ដែលមានអ្នកអានសុទ្ធតែជាអ្នកស្រឡាញ់ជាតិពិតប្រាកដ ។ ប្រាជារាស្ត្រ និងព្រះសង្ឃបានគាំទ្រសារព័ត៌មាននេះយ៉ាងពេញទំហឹង ។ ចំណែកខាងព្រះសង្ឃដែលខំតស៊ូយ៉ាងស្វិតស្វាញមិនខ្លាចស្លាប់ដើម្បីមាតុភូមិរស់នោះ គឺលោកអាចារ្យ ប៉ាង ខាត់ សាស្ត្រាចារ្យភាសាសំស្ក្រឹត, លោកអាចារ្យ សូរ ហាយ ក្រុមជំនុំព្រះត្រៃបិដក, លោកគ្រូអាចារ្យ ខៀវ ជុំ គង់នៅវត្តលង្កា ព្រះងារចារ្យ ហែម ចៀវ សាស្ត្រាចារ្យភាសាបាលី និងសាមណសិស្សនៅសាលាបាលីជាន់ខ្ពស់ជាច្រើនអង្គទៀតជួយផង ។ ព្រះសង្ឃទាំងអស់អង្គនេះហើយ ដែលធ្វើឱ្យទាហានខ្មែរភ្ញាក់រលឹកលែងឈ្លោះទាស់ទែងគ្នាដោយខុសបែបបទ ។ ក្រុមទាហានបារាំងកាចសាហាវណាស់មិនស្គាល់ច្បាប់ទម្លាប់អ្វីសោះឡើយ ។ បងប្អូនខ្មែរយើងស្អប់ខ្ពើមមិនឱ្យកូនទេ ។ ដូច្នេះហើយ បានជាអ្នកស្រុកស្រែចំការហាមប្រាមមិនឱ្យកូនធ្វើទាហានទេ ព្រោះខ្លាចគេស្អប់រហូតមកដល់សព្វថ្ងៃ ។ ក្រុមទាហានទាំងនោះចូលទៅដល់ភូមិណា ភូមិនោះមុខជាហិនហោចទ្រព្យសម្បត្តិមិនខាន ។ នេះជានយោបាយបំបែកបំបាក់ដើម្បីត្រួតត្រារបស់ពួកចោរព្រៃបារាំងសេស ។

ឆ្នាំ ១៩៤០ កងទ័ពជប៉ុនក៏បានមកដល់ (សូមមើលសៀវភៅគុកនយោបាយរបស់លោក ប៊ុណ្ណ ចន្ទម៉ុល បើចង់ជ្រាបច្បាស់) ដើម្បីវាយកំចាត់សត្រូវរបស់ខ្លួន គឺបារាំង, អាមេរិកាំង, អង់គ្លេសនៅឥណ្ឌូចិនទាំងមូល ។ ពេលនោះកងទ័ពបារាំងមានកម្លាំងខ្សោយណាស់ទៅហើយ ។ ខ្មែរយើងឃើញដូច្នោះក៏ចូលទំនាក់ទំនងនឹងជប៉ុន ដើម្បីឱ្យគេជួយ ពួកជប៉ុនក៏យល់ព្រមតាមសេចក្តីស្នើរបស់លោក សឺង ង៉ុកថាញ់ ដែលជាអ្នកតំណាងឱ្យក្រុមបដិវត្តន៍ខ្មែរ ។

នៅពេលទេសនាម្តងៗ ព្រះអាចារ្យ ហែម ចៀវ បានលើកយកពុទ្ធភាសិតសំខាន់ៗ ដែលទាក់ទងនឹងជីវភាពរបស់ប្រជារាស្ត្រ ដើម្បីឱ្យជ្រាបច្បាស់ បាននឹងដឹងច្បាស់នូវគោលបំណងនៃព្រះបរមគ្រូរបស់យើង ។ ពុទ្ធភាសិតទាំងនោះគឺ : កុំធ្វើឱ្យមនុស្សចង្អៀតលោក ត្រូវគិតបច្ចុប្បន្នឱ្យបានសុខជាមុនព្រោះថាបើបានសុខក្នុងបច្ចុប្បន្នហើយ អនាគតមុខជាសុខហើយ ។ កន្លងសេចក្តីទុកបាន ព្រោះព្យាយាមខ្ជាប់ខ្ជួន ។ មានតែខ្លួនយើងទេ ដែលជាទីពំនឹងបាន ។ បុគ្គលមិនគប្បីសេពគប់នូវមិត្តដ៏លាមកទាំងឡាយឡើយ ។ មិនគប្បីសេពគប់នូវបុរសដ៏ទាបថោកទាំងឡាយឡើយ គប្បីសេពគប់នឹងកល្យាណមិត្តទាំងឡាយ ។ បុគ្គលមិនគួរគប្បីអាស្រ័យអ្នកដទៃចិញ្ចឹមជីវិតឡើយ ។

ពុទ្ធភាសិតទាំងអស់នេះ លោកចង់ឱ្យប្រជារាស្ត្រមានសេរីភាពដោយពឹងផ្អែកលើខ្លួនឯងជាមូលដ្ឋាន ។ ក្រៅពីលើកពុទ្ធភាសិត លោកបានទាញនូវឧទាហរណ៍ល្អៗពីប្រទេសនានា ដែលគេចេះកសាងជាតិឱ្យបានរុងរឿងគ្រប់វិស័យ ។ មិនត្រឹមតែប៉ុណ្ណោះ លោកអាចារ្យមានស្មារតីឱ្យខ្មែរក្រោកឈរប្រយុទ្ធយកឯករាជ្យពីបារាំងប៉ុណ្ណោះទេ លោកថែមទាំងបានបណ្តុះស្មារតីកូនខ្មែរឱ្យស្រឡាញ់ការសិក្សាឱ្យយល់ពីតម្លៃនៃវិជ្ជាថែមទៀតផង ។ មហាវិស្សមកាលក៏ចូលមកដល់... ព្រះអាចារ្យ ហែម ចៀវ បាននិមន្តទៅវត្តកំណើត ដើម្បីសួរសុខទុក្ខញាតិញោម និងភិក្ខុសាមណេរឯទៀត ដែលរាប់អានគ្នា ។

(តទៅលេខក្រោយ)


ANGKOR AUTO SERVICE, INC.

ហាងជួសជុលរថយន្ត "អង្គរ"

4835 N. 16th Street.
Philadelphia, Pa 19141

Tel : (215) 455-7810
Ricky : (215) 485-1425

Specializing in Body Kit and Custom Paint

ជំនាញខាងជួសជុលតួរថយន្ត
និងបាញ់ថ្នាំដាក់ក្បាច់តាមបំណងភ្ញៀវ

RICKY
Hand Ph.: Ricky 215-485-1425

មានបទពិសោធន៍២០ ឆ្នាំ
ជាជាងរថយន្តមានសញ្ញាប័ត្រ
វាយតម្លៃការងារដោយឥតយកថ្លៃ
ហើយយើងជួយសន្សំប្រាក់តម្លៃ
បន្ថយរបស់អ៊ិនសួរិន បានផង
យើងផ្តល់សេវាគ្រប់យ៉ាង :
-State inspection
-Insurance Claims
-Auto Glass Repairs
-Auto Frame Repairs
-Custom Painting
-Auto A/C

មុនពេលជួសជុល



ក្រោយពេលជួសជុល





បើកពីម៉ោង ៩ ព្រឹក
ដល់ម៉ោង៥ល្ងាច ពីថ្ងៃ
ច័ន្ទ ដល់ ថ្ងៃ សៅរ៍
ចុះតម្លៃជូន 10 % បើបង្ហាញប័ណ្ណពាណិជ្ជកម្មនេះ

# A.B.C MONEY TRANSACTION, INC

# $ ក្រុមហ៊ុនផ្ញើប្រាក់ A.B.C

## តម្លៃសំរាប់ផ្ញើទៅស្រុកខ្មែរ

| | | ភ្នំពេញ | តាមខេត្ត |
|---|---|---|---|
| ផ្ញើ $100 | យកកម្រៃ | $4.50 | $5.50 |
| $200 | យកកម្រៃ | $9.00 | $11.00 |
| $300 | យកកម្រៃ | $13.50 | $16.50 |
| $500 | យកកម្រៃ | $16.00 | $17.00 |
| $1000 | យកកម្រៃ | $25.00 | $26.00 |
| $1500 | យកកម្រៃ | $35.00 | $36.00 |
| $2000 | យកកម្រៃ | $42.00 | $43.00 |
| $2200 | យកកម្រៃ | $46.00 | $47.00 |



សូមកុំភ្លេចទាក់ទងការិយាល័យក្រុមហ៊ុន ABC ដែលនៅជិតលោកអ្នក ប្រសិនបើមានបំណងចង់ផ្ញើប្រាក់ទៅស្រុកខ្មែរ ឬក៏ទូរស័ព្ទមកយើងតាម

### នៅរដ្ឋ VIRGINIA សូមទាក់ទង

**ABC MONEY TRANSATION ,INC.**

8 locations to serve you in Virginia

- 6757 Willson Blvd.-Ste.#25 Tel : 703.534.2600
- 4291 Holland Rd-Ste.#111 Tel : 757.474.9400
- 10428 Ridgefield Pkwy Tel : 804-740-2454
- 2519 W . Mercury Blvd . Tel : 757.265.6305
- 23520 Overland Dr. Tel : 703.661.6666
- 6314 Rigsby Rd. Tel : 804.288.2988
- 7252 Arlingston Blvd . Tel : 703.641.0778
- 6217 W. Broad St. Tel : 804.288.6988

**ARIZONA**
- 4215 N 19th Ave. . Tel : 602.266.6744

**GEOERGIA**
- 4897 Buford Hwy. Ste. 202. Tel: 770.457.7888

**ILLINOIS**
- 4871 N. Broadway . Tel :773.989.7332

**MASSACHUSETTE**
- 996 Dorchester Ave. Tel:617.825.9380
- 1365-1377 Dorchester Ave. -Ste.4,Froor 1 .Tel : 617.265.4600

**MINNESOTA**
- 2718 Nicollet Ave . S.- Ste. 102 B
- Tel : 612.871.4731
- 6350 Brooklyn Blvd . Tel : 763.503.3947

**NORTH CAROLINA**
- 3000 Central Ave. Ste . #9 . Tel : 704-532-4420

**OREGON**
- 6908 N.E. Sandy Blvd . Tel : 503.281.8088

**PHILADFELPHIA**
- 5520 . Whitaker Ave. -Unit 2 . Tel : 215.831.9794
- 571 Adams Ave . Ave.#4 . Tel : 215.342.6623

**TEXAS**
- 1818 E . Pioneer Pkwy. Ste.156 . Tel : 317.461.1461
- 2615 W . Pioneer Pkwy. Ste.136 . Tel : 214.788.2817
- 5302 E . Belknap St.- Ste.D6 . Tel : 817.831.4836
- 3538 W . Walnut St. Tel : 972.272.2253
- 11205 Bellaire Blvd . Tel : 281.561.6600
- 10909 Scarsdale Blvd . Tel : 281.481.2700
- 13480 Veterans Memorial Dr.-Ste. F2. Tel: 281.587.0807

**WASHINTON STATE**
- 766 S.38th St,. Tel : 253.475.2847
- 3818 S.Graham St.-Ste. C Tel : 206.721.2070

## ក្រុមហ៊ុនទទួលផ្ញើប្រាក់ទៅកម្ពុជា

ABC ជាក្រុមហ៊ុនផ្ញើប្រាក់តែមួយគត់នៅស្រុកខ្មែរ ដែលមានការប្រគល់ប្រាក់ដល់ផ្ទះ

- ស្របច្បាប់
- រហ័សទាន់ចិត្ត
- ធានារ៉ាប់រង និងជូនប្រាក់ទៅដល់ផ្ទះ
- កំរៃផ្ញើថោកជាងកន្លែងដទៃ

### ក្រៅពីការផ្ញើប្រាក់ក្រុមហ៊ុនមានលក់

PHONE CARD និង PINLESS សំរាប់ទូរស័ព្ទទៅស្រុកខ្មែរ ដែលផលិតដោយក្រុមហ៊ុន ABC ផ្ទាល់ មានគុណភាពល្អ ហើយជាពិសេស CARD របស់យើងនឹងទុកបានរហូត មិនអស់កំណត់កាលឡើយ ( NEVER EXPIRED) ។

ត្រូវការអ្នកសហការ (AGENTS ) ជាមួយយើងទូទាំងសហរដ្ឋអាមេរិក និងបានទទួលប្រាក់ចំណូលយ៉ាងខ្ពស់ !

ព័ត៌មានបន្ថែមសូមទាក់ទង CHET THACTHER តាមទូរស័ព្ទ និងអាស័យដ្ឋានខាងក្រោម :

Office : 714-590-8740 Fax : 714-590-8776
Cell: 714-603-3509 Toll Free : 1-877-939-0110

ABC MONEY TRANSATION, INC
12019 Garden Grove Blvd., Ste.#204
Garden Grove , CA 92843
chesterthatcher@yahoo.com

តមកទំព័រទី ០១

# ហ៊ីបហុបខ្មែរហ្វីឡាដែលហ្វៀ...

ដែលជាសិល្បៈរបស់អាមេរិកាំងស្បែកខ្មៅ បានក្លាយជាចំណូលចិត្តរបស់យុវជនជាទូទៅ ហើយហូរហៀរដល់យុវជនខ្មែរ ដែលបានយកសិល្បៈនេះជាវប្បធម៌ថ្មីរបស់ខ្លួនទៀតផង ។ នៅប៉ុន្មានឆ្នាំចុងក្រោយនេះ ហ៊ីបហុប បានត្រូវយុវជនខ្មែរ ហ៊ានបញ្ចេញស្នាដៃនៅតាមបន្ទប់ក្នុងដីក្រោមផ្ទះ តាមជ្រុងផ្លូវក្រខ្វក់នៃតំបន់អ្នកក្រ ហើយ "ធីបស៊ី" ជារង្គសាលខ្មែរដ៏តិចតួចដែលឱ្យឱកាសហ៊ីបហុបខ្មែរ ទៅប្រកួតស្នាដៃជាមួយយុវជនអាមេរិកាំងស្បែកខ្មៅបាន ។

នាខែឧសភាឆ្នាំនេះ ហ៊ីបហុបខ្មែរ ត្រូវកាសែត ហ្វីឡាដែលហ្វៀ ប្រចាំសប្តាហ៍ PW ផ្សាយរូបសិល្បករហ៊ីបហុបខ្មែរមួយ ក្រុមនៅទំព័រមុខ ហើយ រៀបរាប់យ៉ាងវែងនូវជីវិតអ្នក"រ៉ាប"(អ្នករាំ និងច្រៀង) ដែលបានឆ្លងកាត់វាសនានៃសហគមន៍អ្នកក្រមិនថា អាមេរិកាំង ឬខ្មែរនោះទេ ។ ផ្សាយជាភាសាអង់គ្លេស ខ្មែរហ្វីឡាតិចណាស់ ដែលបានយល់ជម្រៅនៃការតស៊ូក្នុងជីវិតរបស់យុវជនខ្មែរជាទូទៅ ដែលមិនបានទទួលវប្បធម៌ដើមពីម្ដាយឪពុក ដែលភាគច្រើនខ្មាសអៀន ពីព្រោះពុំមែនជាសិល្បៈនៃចំណូលចិត្តរបស់ខ្លួន ។

ឆ្នាំនេះសមាគមខ្មែរ រួមទាំង "ASIAN ART INITIATIVE" បានណែនាំឱ្យមានការបង្ហាញសិល្បៈនៃចំណូលចិត្តរបស់យុវជនសម័យថ្មី ក្រុម "អេស៊ីអាយ AZI" បានក្លាយទៅជាតារានៃយុវវ័យនាឱកាសដ៏កម្រនោះទាំងពីរដង ។

វប្បធម៌នៃការសាក់រូបតាំងពីក្បាលរហូតដល់កំប៉េះគូថ ស្លៀកខោ "ជីន" ធំ ហើយវែងជាងជើង ពាក់អាវមិនបិទឡេវចំហរទ្រូង ចំហរពោះនិងគូថ ពាក់មួកបញ្ឆិត ជាវប្បធម៌ថ្មីនៃយុវវ័យ ហើយខ្លះមានអាយុចូលប្រដៅកូន, ថាមេគ្រួសារក្រមានជម្ងឺជាប្រចាំ, ថាមិនព្រមមករៀនវិជ្ជាអប់រំដល់គ្រួសារ...។ល។ គេអាចលើកដាក់កំហុសនៃអំពើអវិជ្ជមានរបស់យុវវ័យទៅលើមេគ្រួសារយ៉ាងងាយ តែងដាក់កំហុសទៅលើសហគមន៍មួយ ដែលមកដុះដាលនៅបរទេសយ៉ាងតិចតួច ។ វប្បធម៌




ជង្រុកសិល្បៈបូរាណខ្មែរមួយឈ្មោះ "Khmer Art Gallery" ថារូបរាងជាខ្មែរ តែពុំមានអ្វីសែសសល់សម្រាប់មកបង្ហាញឱ្យបានដូចពុកម៉ែ ដូនតា ទៀតទេ ។

"អេស៊ីអាយ ហ្វាឡស" មានមោទនភាពចំពោះចំណូលចិត្តរបស់ខ្លួន ហើយនិយាយយ៉ាងចំហរពីការ ប្រឈមមុខនឹងជីវិតដល់លំបាករបស់ខ្លួន ដោយគ្មានលាក់លៀម ប្រាប់ពីដំណើរជីវិតដ៏គ្មានខ្មាសដល់អ្នកកាសែត PW ដើម្បីផ្សាយ ហើយចម្រៀងហ៊ីបហុបរបស់ខ្លួនទៀតសោត ក៏សុទ្ធជាសារនៃជីវិតពិតរបស់ខ្លួន ជូនដល់សហគមន៍ដែលរស់នៅជុំវិញខ្លួន ។ សារទាំងនោះបានឱ្យសាធារណជនដឹងខ្លះៗ អំពីជីវិតអ្នករស់តាមចិញ្ចើមថ្នល់នាស្រុកអាមេរិក ដែលអ្នកនៅឆ្ងាយនឹកមិនដល់ ដូចជាការលក់គ្រឿងញៀន, ការប្រទូសរ៉ាយគ្នារវាងក្រុម Gang ខ្មៅ និងលឿង ឬស្បានីស, ការលែងខ្លាចជាប់គុកនាអំឡុងឆ្នាំ១៩៩០ ហើយចេះតែវិវត្តន៍ដោយគ្មានការគ្រប់គ្រងរហូតមកដល់សព្វថ្ងៃ ។

២០ឆ្នាំបន្តមក អ្នកទាំងនោះងាកសម្លឹងទៅក្រោយមើលមិនឃើញមាននរណាចង់យល់ពីខ្លួន ក្រៅពីការសងសឹក ពីការជាប់គុក ពីការជាប់គ្រឿងញៀន ហើយជីវិតសិក្សាក៏បានស្គាល់តិចតួច ព្រោះសហគមន៍ចាត់ទុកថា អាក្រក់ ហើយបោះបង់គ្នាចោលស្រឡះតែម្តង ។ ម្លោះហើយខ្លះនិយាយថា "រស់ក្នុងចំណោមអ្នកក្រ គឺជាជីវិតពិតរបស់ពួកគេ" ឬខ្លះទៀតថា "ប្រសិនបើខ្ញុំមិនក្រទេនោះ ប្រហែលជាខ្ញុំមិនបានច្រៀងរាំ ហ៊ីបហុប នេះទេ..."។ សិល្បករជាច្រើនសម្តែង ហ៊ីបហុបមានប្រជាប្រិយ ហើយលក់ថាសចម្រៀងបានលុយក្រៃល តែយុវជនខ្មែរហ៊ីបហុប ដើម្បីស្វែងរកឱ្យគេយល់ពីជីវិតរបស់ខ្លួន។ នៅឆ្នាំនេះមានពន្លឺថា មានគេផ្តើមយល់ពីតម្លៃរបស់ខ្លួនខ្លះៗហើយ ។

ពីការយល់ចិត្តផ្តើមមកដល់ការស្រឡាញ់ថ្នាក់ថ្នម សហគមន៍ខ្មែរនៅត្រូវធ្វើដំណើរច្រើនឆ្នាំទៅមុខទៀត ដោយសហគមន៍យើងមាន









ដល់មជ្ឈិមវ័យទៅហើយដែរ ពុំដែលមានឱកាសនឹងបង្ហាញពីចំណូលចិត្តរបស់ខ្លួនជាសាធារណៈ ពុំដែលមានការលើកដំកើង ហើយក៏គ្មាននរណាចង់យល់ពីពួក "រ៉ាប់" ទាំងនោះដែរ ។ រូបភាពសាមញ្ញដែលសហគមន៍ចងចាំពីពួកគេ គឺក្រុមក្មេងពាល (Gang) កាប់ចាក់, បាញ់សម្លាប់គ្នាតាមផ្លូវសាធារណៈ, ជក់អាភៀនកញ្ឆា, លួច ឬប្លន់ ឬបោះបង់ចោលសាលារៀន...។ល។ គេតែងលើកបន្ទោសចំពោះឪពុកម្តាយថាមិនចេះដែលបានផ្លាស់ប្តូរទាំងស្រុងទៅហើយ ពុំមានអាជ្ញាធរណានឹកទៅដល់សហគមន៍នោះ ក្រៅពីយករូបខ្លួនមួយពេលតែរៀងៗខ្លួន ។ ក្រុម "អេស៊ីអាយ ហ្វាឡស" គឺជាផលិតផលនៃសហគមន៍ខ្មែរ ដែលមកប្រជែងជីវភាពក្នុងរង្វង់សហគមន៍អាមេរិកាំងខ្មៅ ដែលខ្លួនឯងមិនដែលស្គាល់ពីមុនមកសោះ... ៣០ឆ្នាំក្រោយមក "អេស៊ីអាយ" បានបង្ហាញសិល្បៈដែលជាចំណូលចិត្តរបស់យុវវ័យសម័យថ្មីនៅកណ្តាលប្រវត្តិមករស់នៅសហរដ្ឋអាមេរិកនេះ ដោយការមិនទុកចិត្តគ្នា ដោយសារអំពើហឹង្សា កាប់សម្លាប់គ្នា ដោយដាច់ឫសគល់វប្បធម៌របស់ខ្លួនរបស់ខ្លួនថា "នេះជាផលិតផលនៃសហគមន៍ទាំងមូល ដែលបានភ្លេចខ្លួនឯង... ពុំអាចផ្តាច់ចោលបានដោយពុំមានគ្រោះថ្នាក់ដល់ខ្លួនឯងវិញបានឡើយ"។

**ខ្មែរប៉ុស្តិ៍**

FRANK'S TIRES




2624 S. FAIRHILL ST.
(215) 334-2261
OPE N 7 DAYS A WEEK
8 A.M. – 7 P.M.

NEW & USED TIRES
ESTBLISHED SINCE 1984

FOR SALE BY OWNER

HASS´S AUTO ជួសជុលតួឡានដែលបុគ្គលម្ចាស់ហាងចូលនិវត្តន៍-ហាងមានដំណើរការ១៧ឆ្នាំមកហើយ -ពាណិជ្ជកម្មមានលំនឹងល្អគ្រប់រដូវលោកអ្នកអាចទិញតែពាណិជ្ជកម្មក៏បាន-ទិញដីជាមួយនឹងផ្ទះក៏បាន -ទិញទាំងពីររួមគ្នាក៏បាន បើចង់ដឹងច្បាស់សូមទូរស័ព្ទរកឈ្មោះ "នីក"

Owner is retiring. 17 years in business at this location.
Well established business, all seasons are busy.
Option to buy only business, real estate, or both.




Contact Nick: 267-242-7938
615 W. Fisher Ave. Phila, Pa 191203


HONG KONG
SUPERMARKET
FAMER´S BEST
HONG KONG SUPERMARKET
(PA) WEEKLY PROMOTION ITEMS
លក់ចុះថ្លៃពីថ្ងៃ ១១_១៧/មិថុនា/២០១០
ON SALE PERIOD
June/11-17/2010
$2.99 a LB
Newly Renovated.
Added new section .
Clean and Improved
management !
ទើបនឹងកែលំអរថ្មីឡើងវិញ
-បន្ថែមផ្នែកលក់ថ្មីទៀត
បាងស្អាត ហើយបង្កើន
គុណភាពគ្រប់គ្រង
Weekly Sale
លក់ចុះថ្លៃរៀងរាល់សប្តាហ៍
$1.99 a Can
$1.69 a Jar
$3.49 a Tin
$0.99 a LB
$2.99 per LB
$1.79 a LB
59c a LB
$2.99 - LB
$1.69 per Blt
99c per Blt
2 for $5.00
99c per bag
3 bag for $10.00
$2.69 per bag
99c per bag
OPEN
7 DAY
8:00-9:00
571 ADAMS AVE.PHILADELPHIA,PA19120
Tel: 215-7281300 Fax: 215-728-1600
•ចំណាយ $140ដុល្លារ ទទួលបានអង្ករស្រូវស ២៥ ផោន
•ចំណាយ $100ដុល្លារ ទទួលបាននូវភេសជ្ជៈ ឬមីកញ្ចប់មួយប្រអប់(តម្លៃ 8.99)
•ចំណាយ $25 ដុល្លារទទួលបានទឹកសណ្តែកមួយដប ឬទឹកត្រីមួយដប ។

# ស្ត្រីខ្មែរដំបូងបង្អស់ដែលបានធ្វើដំណើរពីប្រទេសបារាំងមកភ្នំពេញតាមផ្លូវគោគ



(តពីលេខមុន)

ដោយ : ពិន នារីពិទូ

•••ដោយមានការបង្ហាញផ្លូវពីភ្នាក់ងារប៉ូលីសយើងក៏បានធ្វើដំណើរទៅដល់គោលដៅដោយសុវត្ថិភាព។ ទីក្រុងវ្លាឌីមា Vladimir មានទិដ្ឋភាពដ៏ស្រស់ស្អាតព្រមទាំងមានសណ្ឋាគារដ៏ប្រណិត២ ប្រជាជនភាគច្រើនអាចទំនាក់ទំនងជាភាសាអង់គ្លេសបានខ្លះៗ បន្ទាប់មកយើងបានជួលបន្ទប់ស្នាក់នៅសំរាប់មនុស្សពីរនាក់ដែលមានតំលៃ ១៥យូរ៉ូក្នុងមួយយប់។ យើងបានដើរលំហែរក្នុងទីក្រុងវ្លាឌីមា Vladimir ធ្វើឱ្យអារម្មណ៍ធូរស្រាលជាងនៅទីក្រុងមូស្គូ ពីព្រោះច្បាប់នៅទីក្រុងមូស្គូ រឹតបន្តឹងចំពោះជនបរទេស ខណៈនោះពួកយើងគ្មានលិខិតបោះត្រាពីភ្នាក់ងារអន្តោប្រវេសន៍ ប៉ុន្តែពួកយើងមានលិខិតផ្សេងៗដែលបោះត្រាពីភ្នាក់ងារពន្ធគយ។ ចំណែកការបើកបរមានការប្រុងប្រយ័ត្នយ៉ាងខ្លាំង ដោយប្រជាជននៅទីក្រុងមូស្គូបើកបរក្នុងល្បឿនលឿន ។ ទីក្រុងវ្លាឌីមា Vladimir មានចំណោមនោះមានវិហារ Cathedral ធំៗចំនួនពីរដែលត្រូវបានចុះបញ្ជីជាកេរ្តិ៍ដំណែលវប្បធម៌ពិភពលោករបស់អង្គការ យូណេស្កូUNESCO ក្នុងចំណោមកេរ្តិ៍ដំណែលវប្បធម៌ពិភពលោកទាំង២៣របស់ប្រទេសមហាអំណាចរុស្ស៊ី អ្នកទេសចរណ៍ជាច្រើននិយមទស្សនាតំបន់ប្រវត្តិសាស្ត្រនេះ ដែលនាំមកនូវប្រភពចំណូលផ្នែកសេដ្ឋកិច្ចជាច្រើនដល់ប្រទេសនេះ។

នៅរដូវនេះប្រទេសអឺរ៉ុបក៏ដូចជានៅវ្លាឌីមា (Vladirmir) តែងតែរំខានដោយសារភ្លៀង ។ ហេតុនេះគួរត្រៀមថ្នាំបង្កាឱ្យបានគ្រប់គ្រាន់ដើម្បីការពារជំងឺផ្ដាសាយ និងគ្រុនក្ដៅជាយថាហេតុ។

យើងបានចាកចេញពីទឹកដីចិញ្ចៀនមាសដោយឆ្ពោះដំណើរទៅទីក្រុងនីស្នី Nizhny Novgorod ដែលមានចំងាយពីទីក្រុង Vladirmir ២៤២ គីឡូម៉ែត្រ មានប្រជាជនរស់នៅជាងមួយលាននាក់ និងជាទីក្រុងធំលំដាប់ទីបួនរបស់ប្រទេសរុស្ស៊ី ស្ថិតតាមបណ្ដោយទន្លេវ៉ុលហ្គា Volga ដែលជាទន្លេដែលធំជាងគេនៅទ្វីបអឺរ៉ុប នីស្នី Nizhny ជាទីក្រុងសេដ្ឋកិច្ចដំណើរអស់ប្រាំពាន់គីឡូម៉ែត្រមកហើយ ដែលនេះជាមោទនភាពរបស់ពួកយើងក្នុងដំណើរផ្សងព្រេងក្នុងចំងាយផ្លូវដ៏វែងឆ្ពោះទៅមាតុប្រទេស។ សណ្ឋាគារខ្លះនៅកាហ្សាន់ Kazan មិនអនុញ្ញាតិឱ្យពួកបរទេសស្នាក់នៅ ប៉ុន្តែមិនមែនទាំងអស់នោះទេ សណ្ឋាគារ olga បានអនុញ្ញាតិឱ្យភ្ញៀវបរទេស និងក្នុងស្រុកចូលមកសំណាក់បាន។

ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៦ : ថ្ងៃនេះមេឃស្រអាប់ហាក់ចង់បង្អុរភ្លៀង យើងបន្តដំណើរទៅមុខក៏បានជួបប្រទះវិហារសាសនាអ៊ិស្លាមមួយដ៏ប្រណិតដ៏គួរឱ្យភ្ញាក់ផ្អើលដែលបានស្ថាបនានៅចំកណ្ដាលប្រទេសរុស្ស៊ី ។ ថ្ងៃស្អែកពួកយើងនឹងបន្តដំណើរឆ្ពោះទៅទីក្រុង Perm ដែលមានចំងាយ៦៧០គីឡូម៉ែត្រ ដោយបើកបរអស់រយៈពេល១២ម៉ោងឆ្លងកាត់ភ្លៀង និងភាពងងឹតនាពេលរាត្រី ពួកយើងក៏សំរេចចិត្តឈប់សំរាកនៅផ្ទះសំណាក់មួយកន្លែង។

ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៦ : ថ្ងៃយើងបានមកដល់ទីក្រុង Perm តាមកំណត់មិត្តភក្ត្រ័ជាច្រើនយ៉ាងខ្លាំង រទេះសេះរួមទាំងសត្វគោបានដើរឆ្លងកាត់ផ្លូវដោយសេរី ។ នៅតាមផ្លូវនៃប្រទេសរុស្ស៊ីយើងបានប្រទះឃើញគ្រោះថ្នាក់ចរាចរណ៍ជាច្រើនដែលបណ្ដាលមកពីការបើកបរមិនគោរពច្បាប់ចរាចរណ៍។

(តទៅលេខក្រោយ)





ស៊ីលវីយ៉ា Sylvia និងអូរេលី Aurélie ថតនៅមុខទន្លេវ៉ុលហ្គា Volga







ផ្ទៃដីសរុបចំនួន ៣០៨ គីឡូម៉ែត្រក្រឡា និងមានប្រជាជនរស់នៅប្រមាណ ៣១៥.៩៥៤នាក់ ទីក្រុងប្រវត្តិសាស្ត្រនេះរំលេចទៅដោយវិមានប្លែកៗ នៃស្ថាបត្យកម្ម នាសតវត្សទី១២ ដល់សតវត្សទី១៨ និងប្រជុំទៅដោយវិហារជាច្រើនរំលេចឡើងនូវក្បាច់រចនាគួរឱ្យស្ញប់ស្ញែង ហើយក៏ជាកន្លែងសក្ការៈតាមបែបជំនឿសាសនារបស់ប្រជាជនរុស្ស៊ី ដែលបានសាងសង់អស់ជាងមួយសតវត្សទៅហើយនោះ ទីក្រុងចិញ្ចៀនមាសនេះ ជាទីកន្លែងសំរាប់រំលឹកនូវប្រវត្តិសាស្ត្រ និងព្រឹត្តិការណ៍ពីអតីតកាលដ៏សំខាន់ៗរបស់ប្រទេសរុស្ស៊ីផងដែរ។ ទីក្រុងវ្លាឌីមា Vladimir ត្រូវបានចាត់ទុកជាចិញ្ចៀនមាសនៃប្រទេសរុស្ស៊ី ព្រោះសំបូរទៅដោយកេរ្តិ៍ដំណែលពីបុរាណ នៅក្នុងដឹកជញ្ជូន និងវប្បធម៌ដ៏សំខាន់របស់ប្រទេសរុស្ស៊ី។ យើងបានស្វែងរកសណ្ឋាគារដើម្បីស្នាក់នៅ ដោយនៅទីនោះមានសណ្ឋាគារប្រណិតៗតិចតួច ប៉ុន្តែមានតំលៃថ្លៃ នីស្នី Nizhny ជាទីក្រុងបុរាណ និងប្រកបដោយវិហារសាសនាធំៗ។ បន្ទាប់មកយើងបានដើរលំហែរតាមដងទន្លេទន្លេវ៉ុលហ្គា Volga ដើម្បីស្រូបយកខ្យល់បរិសុទ្ធ។ បន្ទាប់ពីឆ្លងកាត់ទីក្រុង នីស្នី Nizhny ថ្ងៃស្អែកពួកយើងនឹងបន្តដំណើរឆ្ពោះទៅទីក្រុង កាហ្សាន់ Kazan ។

ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៦: បើកបរអស់រយៈពេល១៨ម៉ោងយើងក៏បានមកដល់កាហ្សាន់ Kazan ដោយសារផ្លូវស្ថិតក្នុងការជួសជុល ធ្វើឱ្យមានការយឺតយ៉ាវក្នុងការបើកបរ ។ យើងបានធ្វើបានទូរស័ព្ទមកដើម្បីអបអរនូវថ្ងៃពិសេសជាមួយពួកយើងទាំងពីរក្នុងការធ្វើដំណើរអស់ចំងាយ៥០០០ គីឡូម៉ែត្រមកហើយនេះ។ ពួកយើងបានបើកបរបន្តឆ្ពោះទៅ Izhevsk ក្នុងចំងាយផ្លូវ៣៧០គីឡូម៉ែត្រ ដោយបើកបរអស់រយៈពេល៥ម៉ោង ដោយមានភ្លៀងជាលំដាប់។ យើងបានធ្វើដំណើរដោយថ្មើរជើងនៅក្នុងទីក្រុងដើម្បីទស្សនារោងអូប៉េរ៉ា ការិយាល័យប្រៃសណីយ និងពិសារអាហារក្នុងភោជនីយដ្ឋានដែលបញ្ជីឈ្មោះម្ហូបសរសេរជាភាសាអង់គ្លេស រួមទាំងអ្នកបំរើដ៏រាក់ទាក់រង់ចាំស្វាគមន៍ពួកយើង។ តាមផ្លូវក្នុងទីក្រុង Perm មានការបើកបរខ្វាត់ខ្វែងដោយសេរី និងមានត្រាកទ័រ រថយន្តធំៗដូចជាឡានដឹកសំរាម ឡានដឹកទំនិញបានបញ្ចេញផ្សែងពុលដល់បរិស្ថាន






NEW PHNOM PENH RESTAURANT

○មីបំពងគ្រឿងសមុទ្រ ○គុយទាវគោក -គុយទាវសាច់គោ

○ផាត់ថៃ ○ឡុកឡាក់ ○មាន់ឆាខ្ញី

○បាយសាច់ជ្រូកអាំង ○មីកន្ទាំងសាច់គោ ○បាយឆាសាច់គ្រប់មុខ

TEL.(215) 389-2122

2301 South. 7th Street. Philadelphia, PA 19148
( 7th & Wolf)




ឱសថស្ថានខ្មែរ

Sav-Mor PHARMACY

Sam EA R.Ph.

2232 S. 7th St. (7th & Wolf) Philadelphia, Pa 19148

Tel: 215.467.1220 Fax: 215.467.1447



បំរើលោកអ្នកដោយមិត្តភាព និងធានចិត្ត

▸▸Sav-Mor គឺជាឱសថស្ថានបំរើ ការចែកចាយថ្នាំ ហើយអាចពន្យល់ពីរបៀបប្រើប្រាស់ថ្នាំ តាមវេជ្ជបញ្ជាជាភាសាខ្មែរបាន

▸▸យើងទទួលយកនូវ MEDICARE MEDICAID និង INSURANCES ជាច្រើនទៀតផង យើងមានលក់កាត សំរាប់ទូរស័ព្ទទៅស្រុកខ្មែរ ឬទៅអន្តរជាតិ

*Accept most insurance plans including Medicare & Medicaid

*Easy Prescription transfer

*Inside. Prepaid phone card. Call Cambodia.

# NEW GOLDEN PALACE

**SEAFOOD RESTAURANT**
**801-21 Washington Avenue.**
**Philadelphia, Pa 19147**

**Tel: 215-627-2822**

Business Hours: Monday–Sunday. 10 a.m.–10 p.m.

## សូមអញ្ជើញគ្រោងពិធីរបស់លោកអ្នកជាមួយនឹងយើងខ្ញុំ

*Plan your next event here!*



- *Wedding Reception* — ពិធីមង្គលការ
- *Birthday Parties* — បុណ្យខួបកំណើត
- *Business Meetings* — ប្រជុំការងារជំនួញ
- *Private Parties* — ពិធីជប់លៀងឯកជន
- *Fundraisers* — បុណ្យរៃអង្គាសប្រាក់
- *We Accept Reservation for Holidays* — យើងទទួលឱ្យកក់កន្លែងធ្វើពិធីនៅថ្ងៃឈប់បុណ្យទានបាន

## យើងបំរើម្ហូប ឌិម ស៊ុម រាល់ថ្ងៃ ពីព្រឹកដល់ល្ងាច



**We Serve Dim Sum Daily All Day Long &**



**Also Try Our Vietnamese Phở**

កុំភ្លេច ភ្លក់ "ហ្វើ" វៀតណាមរបស់យើង

**From 10 a.m. – 10 p.m.**

## ពិធីជប់លៀងល្ងាចពិសេស ជាមួយក្រុមគ្រួសារ

## ROYAL FAMILY DINNER PACKAGE

**សំរាប់៦នាក់-ម្ហូប៧មុខ- $78**
**DINNER FOR 6 - 7 Entrées $78**



1. Vietnamese Spring Roll
2. Sweet Sour Pork Chops
3. Seafood Bean Curd Soup
4. Lobster with Ginger & Scallion
5. Steam Fish
6. House Special Fried Rice
7. Seasonal Fruit

**សំរាប់៨នាក់-ម្ហូប៨មុខ- $98**
**DINNER 8 – 8 Entrées $98**

1. Palace Appetizer
2. Shrimp Hot & Sour Soup
3. Baby Claims with Black Bean Sauce
4. Sautéed seafood with Chinese Vegetables
5. Lobster with Ginger & Scallion
6. Steam Fish
7. House Special Lo Mein
8. Seasonal Fruit

**សំរាប់១០នាក់-ម្ហូប៩មុខ- $128**
**DINNER 10 – 9 Entrées $128**

1. Fried Shrimp Rolls
2. Salt Baked Shrimp
3. Seafood with Sweet Corn Soup
4. Seafood Bird's Nest
5. Crispy Fried Chicken
6. Double Lobsters with Ginger Scallion
7. Steam/Fried Fish Tilapia
8. House Special Fried Rice
9. Seasonal Fruit

# COMPUTER+ LLC

SURVEILLANCE SYSTEM, COMPUTER RETAILER, REPAIR & SERVICES



ជំនាញការងារដំឡើងកុំព្យូទ័រ លក់គ្រឿងកុំព្យូទ័រ
និងដាក់គ្រឿងថតវីដេអូសំរាប់ការពារសន្តិសុខ



REMOTE VIEWING

Remote Monitoring, Recording, Controlling through Internet from *anywhere* at *anytime*



*Stand-Alone System*



*PC-Base System*





*HOME or VACATION*



On the ROAD

5709 N. 5th St., Phila, PA 19120 Open: *Mon-Sat; 10am—6:00pm*

*Peter Hong Ching* * Tel: (215) 276-7000 * Fax: (215) 276-7001

E-mail: peterchng_99@yahoo.com www.computerplusllc.com

# Nationwide

Insurance & Financial Service

## សេវាធានារ៉ាប់រង និងហិរញ្ញវត្ថុ

We offer Cheap Price for Every Client

## យើងធ្វើជូនគ្រប់ភ្ញៀវដោយតម្លៃថោក

| | |
|---|---|
| Business Liability Insurance | ធានារ៉ាប់រងជំនួញលោកអ្នក |
| Home Insurance | ធានារ៉ាប់រងផ្ទះសម្បែង |
| Health Insurance | ធានារ៉ាប់រងសុខភាព |
| Auto Insurance | ធានារ៉ាប់រងរថយន្ត |
| Life Insurance | ធានារ៉ាប់រងជីវិត |

Discount 30% when you purchase Home & Auto Insurance

ចុះតម្លៃ ៣០ % បន្ថែមបើលោកអ្នកទិញ
ធានារ៉ាប់រងផ្ទះ និងរថយន្តរួមគ្នា

South Philadelphia office:
600 Washington Ave Suite #8 Philadelphia, PA 19147
Tel: (215) 463-1257 , Fax: (215) 463-2036

ឌឹ ខេមបូឌា ដេលី The Cambodia Daily

# Chevrin No Vote on Transparency Scrutinized

By Simon Marks
THE CAMBODIA DAILY

During Chevron's annual board meeting last week, just 7 percent of the US oil giant's shareholders voted in favor of disclosing all payments made to host governments on the grounds that doing so could jeopardize the "sanctity of existing contracts" and, therefore, harm the company's competitiveness.

But a coalition of NGOs in Cambodia, where Chevron is currently exploring in off-shore block A in the Gulf of Thailand, say an agreement to disclose such financial practices could actually serve the company, by improving its international standing.

Chevron's stockholder notice, released after its annual meeting on May 26, said that openly announcing a one off payment could "undermine the efforts of more productive disclosure initiatives, and could put Chevron at a competitive disadvantage" if the host country itself doesn't have a proper disclosure framework.

"[D]isclosure of payments by an extractive company could give rise to legal liability where contractual arrangements and country-specific laws can prohibit such disclosure and could legally prevent Chevron from making such disclosures," Chevron stated, adding that the disclosure of one payment from one extractive company would not provide "critically important information on revenues" to the public.

Oxfam America in December called on Chevron to disclose all payments it has made to governments in the countries it operates, including Cambodia, where oil extraction is expected before the end of 2012.

The international aid agency filed the shareholder resolution to emphasize that the citizens of oil-rich countries have the right to know how their governments spend their oil revenues.

Mam Sambath, chairman of Cambodians for Resource Revenue Transparency, a coalition of civil society organizations, disagreed with the Chevron board's vote on revenue disclosure.

"By disclosing information of payments to host governments it would not significantly impact its competitive position but instead it will promote Chevron's image, increase the stability of host countries and create a better long-term operating environment for Chevron," he said, adding that other companies—namely Norway's Statoil and Canada's Talisman Energy—have managed to disclose payments in all countries where they are operating.

"They have not appeared to suffer from competitive pressures or host government displeasure and any contractual hurdles have been overcome," Mr Sambath said. "Chevron can play a leadership role in the area of financial transparency."

Some industry experts claim that companies can benefit from disclosing payments, as they reduce the risk of being accused of corruption and can show how much they pay in taxes and, therefore, contribute to the wellbeing of society at large.

But very often it is the policy of the least transparent company that dictates, they say.

Nevertheless, in its stockholder notice Chevron said that if the transparency practice was adopted "it could put itself at a competitive disadvantage against other companies that do not similarly disclose payments on a country-by-country basis."

Instead Chevron said it is advocating an alternative approach allowing host governments to take the lead in applying discourse measures so that companies operate under the same guidelines.

The debate surrounding transparency is hot on the heels of the government that has recently been heavily scrutinized by the media, NGOs and donors in order to provide public information on where money from companies operating in the extractive industries is located and how it is accounted for.

Last month the opposition party called on the government to explain its dealings with Australian miner BHP Billiton and French oil firm Total over payments both firms made to do business in Cambodia.

After the request, Prime Minister Hun Sen assigned Cabinet Minister Sok An, who is chairman of the national petroleum authority, as well as Finance Minister Keat Chhon, to answer those questions.

In April, it was announced that BHP was being investigated in the US for corruption charges that many believe stems from payments made in Cambodia. Similar payments from a plethora of other companies that have operated in the country are also untraceable, rights groups say.

Officials at the government's petroleum authority declined to comment for this article.

Mr Sambath said the disclosure of payments made to the government would "empower the people to hold their government accountable for using oil revenues for economic development and basic social service like education and health care."

"Transparency in our oil sector will help to ensure that revenue is managed in an accountable way that benefits all Cambodian people," he said.

"Chevron payment disclosure would provide valuable information to potential investors and citizens in resource-rich countries such as Cambodia for poverty alleviation and economic growth."

# ក្រុមហ៊ុន Chevron គ្មានសំឡេងគ្រប់គ្រាន់ដែលគាំទ្រឱ្យមានការតាមដានពីតម្លាភាព

ដោយ Simon Marks
THE CAMBODIA DAILY

អំឡុងកិច្ចប្រជុំប្រចាំនៃក្រុមប្រឹក្សាគណៈនាយករបស់ក្រុមហ៊ុន Chevrin កាលពីសប្តាហ៍មុនមានតែ៧ភាគរយប៉ុណ្ណោះនៃម្ចាស់ភាគហ៊ុនរបស់ក្រុមហ៊ុនប្រេងអាមេរិកដ៏ធំនេះបានបោះឆ្នោតគាំទ្រឱ្យមានការបង្ហាញពីចំនួនទឹកប្រាក់ទាំងអស់ដែលផ្តល់ទៅឱ្យរដ្ឋាភិបាលម្ចាស់ផ្ទះដោយសារហេតុផលថា ការធ្វើដូច្នេះយ៉ាងប៉ះពាល់ទៅដល់ "ភាពមិនអាចរំលោភបាននៃកិច្ចសន្យាដែលមានស្រាប់" ហើយជាលទ្ធផលអាចប៉ះពាល់ដល់ការប្រកួតប្រជែងរបស់ក្រុមហ៊ុននេះ ។

ប៉ុន្តែសម្ព័ន្ធអង្គការក្រៅរដ្ឋាភិបាលមួយនៅក្នុងប្រទេសកម្ពុជា ជាទីដែលក្រុមហ៊ុន Chevrin បច្ចុប្បន្នកំពុងរុករករ៉ែនៅក្នុងប្លុក A ក្នុងឈូងសមុទ្រថៃនោះនិយាយថា ការយល់ព្រមឱ្យមានការបង្ហាញពីការប្រើហិរញ្ញវត្ថុបែបនេះតាមពិតអាចមានប្រយោជន៍ផ្ទុយពីនោះដោយធ្វើឱ្យមុខមាត់នៅលើឆាកអន្តរជាតិរបស់ក្រុមហ៊ុននេះប្រសើរឡើងវិញបានទេ ។

លិខិតជូនដំណឹងរបស់ម្ចាស់ភាគហ៊ុននៃក្រុមហ៊ុន Chevrin ដែលបានចេញផ្សាយបន្ទាប់ពីជំនួបប្រចាំឆ្នាំរបស់ខ្លួនកាលពីថ្ងៃទី២៦ ខែឧសភានោះបានលើកឡើងថា ការប្រកាសឱ្យដឹងជាចំហពីការផ្តល់ប្រាក់ដែលធ្វើឡើង តែមួយដងនោះអាច "ធ្វើឱ្យប៉ះពាល់កិច្ចប្រឹងប្រែងនៃគំនិតផ្តួចផ្តើមអំពីការបង្ហាញហិរញ្ញវត្ថុដែលមានប្រយោជន៍ជាងនេះ និងអាចធ្វើឱ្យក្រុមហ៊ុន Chevrin មានគុណវិបត្តិផ្នែកប្រកួតប្រជែង" ប្រសិនបើប្រទេសម្ចាស់ផ្ទះខ្លួនឯងមិនមានគោលការណ៍បង្ហាញហិរញ្ញវត្ថុដែលសមស្របទេនោះ ។

ក្រុមហ៊ុន Chevrin បានលើកឡើងថា "ការបង្ហាញពីទឹកប្រាក់ដែលបង់ដោយក្រុមហ៊ុនរុករករ៉ែណាមួយអាចធ្វើឱ្យមានការទទួលខុសត្រូវតាមផ្លូវច្បាប់ដោយកិច្ចព្រមព្រៀងដែលមានកិច្ចសន្យា និងច្បាប់របស់ប្រទេសជាក់លាក់ណាមួយនោះអាចហាមឃាត់ការបង្ហាញបែបនេះ ហើយអាចរារាំងក្រុមហ៊ុន Chevrin ដោយស្របច្បាប់មិនឱ្យធ្វើបង្ហាញបែបនេះ"។

ក្រុមហ៊ុន Chevrin បន្ថែមថា ការបង្ហាញពីប្រាក់ដែលទទួលបានតែមួយលើកពីក្រុមហ៊ុនរុករករ៉ែមួយនឹងមិនផ្តល់ "ព័ត៌មានសំខាន់ស្តីពីប្រាក់ចំណូល" ដល់សាធារណជនទេ ។

កាលពីខែធ្នូ អង្គការ Oxfam America បានអំពាវនាវឱ្យក្រុមហ៊ុន Chevrin បង្ហាញប្រាក់ទាំងអស់ដែលខ្លួនបានផ្តល់ទៅឱ្យរដ្ឋាភិបាលនៅក្នុងប្រទេសមួយចំនួនដែលខ្លួនរកស៊ី រួមទាំងប្រទេសកម្ពុជា ដែលការទាញយកប្រេង ត្រូវគេរំពឹងថា នឹងធ្វើឡើងមិនឆ្នាំ២០១២ ។

ទីភ្នាក់ងារជំនួយអន្តរជាតិនេះបានស្នើឱ្យមានសេចក្តីសម្រេចរបស់ម្ចាស់ភាគហ៊ុននេះដើម្បីបញ្ជាក់ថា ពលរដ្ឋនៃប្រទេសដែលសម្បូរប្រេងមានសិទ្ធិដឹងពីរបៀបដែលរដ្ឋាភិបាលរបស់ខ្លួនចំណាយប្រាក់ចំណូលដែលបានមកពីប្រេង។

លោក ម៉ម សម្បត្តិ ប្រធានអង្គការប្រជាជនកម្ពុជា ដើម្បីតម្លាភាពប្រាក់ចំណូលធនធានដែលជាសម្ព័ន្ធនៃអង្គការសង្គមស៊ីវិល មិនយល់ស្របនឹងការបោះឆ្នោតរបស់ក្រុមប្រឹក្សាគណៈនាយករបស់ក្រុមហ៊ុន Chevrin ពាក់ព័ន្ធនឹងការបង្ហាញប្រាក់នោះទេ ។

លោកបានមានប្រសាសន៍ថា "ដោយការបង្ហាញព័ត៌មាននៃប្រាក់ដែលផ្តល់ទៅឱ្យរដ្ឋាភិបាលម្ចាស់ផ្ទះវានឹងមិនជះឥទ្ធិពលធំដុំលើជំហរប្រកួតប្រជែងរបស់ខ្លួននោះទេ ប៉ុន្តែផ្ទុយទៅវិញវាជួយលើកស្ទួយមុខមាត់របស់ក្រុមហ៊ុន Chevrin បង្កើនស្ថិរភាពរបស់ប្រទេសជាម្ចាស់ផ្ទះ និងបង្កើតបរិយាកាសប្រតិបត្តិការរយៈពេលវែងប្រសើរជាងនេះសម្រាប់ក្រុមហ៊ុន Chevrin " ទៅវិញទេ ។

លោកបានមានប្រសាសន៍បន្ថែមទៀតថា បណ្តាក្រុមហ៊ុនផ្សេងៗទៀតមានដូចជាក្រុមហ៊ុន Statoil របស់ប្រទេសន័រវេ និងក្រុមហ៊ុន Talisman Evergy របស់កាណាដា សុទ្ធតែបានបង្ហាញពីប្រាក់ដែលខ្លួនផ្តល់ទៅឱ្យប្រទេសដែលពួកគេកំពុងធ្វើប្រតិបត្តិការ ។

លោក ម៉ម សម្បត្តិ បានមានប្រសាសន៍ថា "ក្រុមហ៊ុនទាំងនោះហាក់ដូចជាមិនទទួលរងនូវសំពាធផ្នែកប្រកួតប្រជែង ឬក៏ការមិនសប្បាយចិត្តរបស់រដ្ឋាភិបាលម្ចាស់ផ្ទះទេ ហើយបានជំនះឧបសគ្គផ្សេងៗលើកិច្ចសន្យាទៀតផង។ ក្រុមហ៊ុន Chevrin អាចដើរតួនាទីជាអ្នកដឹកនាំផ្នែក តម្លាភាពហិរញ្ញវត្ថុ" ។

អ្នកជំនាញផ្នែកឧស្សាហកម្មមួយចំនួនអះអាងថា ក្រុមហ៊ុនអាចទទួលបានផលប្រយោជន៍ពីការបង្ហាញពីការបង់ប្រាក់ដោយសារវាកាត់បន្ថយហានិភាពនៃការចោទប្រកាន់ពីបទពុករលួយ និងអាចបង្ហាញថា តើពួកគេបង់ពន្ធប៉ុន្មាន ហើយជាលទ្ធផលគឺសុខមាលភាពសង្គមទូទៅ។

អ្នកជំនាញទាំងនោះនិយាយថា ប៉ុន្តែជាញឹកញាប់វាជាគោលនយោបាយនៃក្រុមហ៊ុនដែលមិនមានតម្លាភាពជាអ្នកកំណត់។

ទោះជាយ៉ាងណា នៅក្នុងលិខិតជូនដំណឹងរបស់ម្ចាស់ភាគហ៊ុននោះ ក្រុមហ៊ុន Chevrin បានលើកឡើងថា ប្រសិនបើការអនុវត្តតម្លាភាពត្រូវបានយកមកប្រើ "វាអាចធ្វើឱ្យក្រុមហ៊ុន Chevrin ខ្លួនឯងមានគុណវិបត្តិផ្នែកប្រកួតប្រជែងទល់នឹងក្រុមហ៊ុនដទៃទៀតដែលមិនបង្ហាញពីការបង់ប្រាក់ស្រដៀងគ្នានេះផ្អែកទៅតាមគោលការណ៍ពីប្រទេសមួយទៅប្រទេសមួយ"។

ផ្ទុយទៅវិញក្រុមហ៊ុន Chevrin បានឱ្យដឹងថា ខ្លួនកំពុងគាំទ្រដំណោះស្រាយជាជម្រើសមួយដែលអនុញ្ញាតឱ្យរដ្ឋាភិបាលម្ចាស់ផ្ទះធ្វើជាគំរូក្នុងការអនុវត្តវិធានការបង្ហាញពីការបង់ប្រាក់នេះ ដើម្បីឱ្យក្រុមហ៊ុននានាធ្វើទៅតាមគោលការណ៍ណែនាំដូចគ្នានេះ ។

ការពិភាក្សាជុំវិញតម្លាភាពកំពុងតាមលងជាន់កែងរដ្ឋាភិបាលដែលថ្មីៗនេះត្រូវបានតាមដានយ៉ាងខ្លាំងក្លាដោយបណ្តាញផ្សព្វផ្សាយព័ត៌មាន ក្រុមអង្គការក្រៅរដ្ឋាភិបាល និងប្រទេសផ្តល់ជំនួយ ដើម្បីផ្តល់ព័ត៌មានដល់សាធារណជនស្តីពីកន្លែងដែលរដ្ឋតម្កល់ប្រាក់ដែលទទួលបានពីក្រុមហ៊ុននានាដែលប្រតិបត្តិការក្នុងឧស្សាហកម្មរុករករ៉ែ និងពីរបៀបចាត់ចែងប្រាក់នោះ ។

កាលពីខែមុន គណបក្សប្រឆាំងបានស្នើឱ្យរដ្ឋាភិបាលពន្យល់ពីកិច្ចព្រមព្រៀងរបស់ខ្លួនជាមួយក្រុមហ៊ុនរុករករ៉ែអូស្ត្រាលីឈ្មោះ BHP Billiton និងក្រុមហ៊ុនប្រេងបារាំងឈ្មោះតូតាល់អំពីប្រាក់ដែលក្រុមហ៊ុនទាំងពីរបានផ្តល់ឱ្យរដ្ឋាភិបាលកម្ពុជាដើម្បីបានសិទ្ធិរកស៊ីក្នុងប្រទេសកម្ពុជា ។

បន្ទាប់ពីមានសំណើនេះ លោក ហ៊ុន សែន បានចាត់តាំងលោក សុខ អាន រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រីដែលជា ប្រធានអាជ្ញាធរប្រេងកាតជាតិ ព្រមទាំងលោក គាត ឈន់ រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុឱ្យឆ្លើយតបនឹងសំនួរទាំងនេះ។

កាលពីខែមេសា មានព័ត៌មានប្រកាសឱ្យដឹងថា ក្រុមហ៊ុន BHP កំពុងបានស៊ើបអង្កេតនៅក្នុងសហរដ្ឋអាមេរិកជុំវិញ ការចោទប្រកាន់ពីបទពុករលួយដែលភាគច្រើនជឿថា បណ្តាលមកពីប្រាក់ដែលបានផ្តល់ទៅឱ្យប្រទេសកម្ពុជា។

ក្រុមអង្គការសិទ្ធមនុស្សនិយាយថា ប្រាក់ស្រដៀងគ្នានេះ ដែលបានមកពីក្រុមហ៊ុនជាច្រើនផ្សេងទៀតដែលបានប្រតិបត្តិការក្នុងប្រទេសនេះក៏មិនអាចតាមដានបានដែរ។

ក្រុមមន្ត្រីនៃអាជ្ញាធរប្រេងកាតជាតិរបស់រដ្ឋាភិបាលបានបដិសេធមិនធ្វើអត្ថាធិប្បាយសម្រាប់ចុះក្នុងអត្ថបទនេះទេ ។

លោក ម៉ម សម្បត្តិ បានមានប្រសាសន៍ថា ការបង្ហាញពីប្រាក់ដែលផ្តល់ទៅឱ្យរដ្ឋាភិបាលនឹង "ពង្រឹងអំណាចប្រជាជនដើម្បីឱ្យរដ្ឋាភិបាលទទួលខុសត្រូវចំពោះការប្រើប្រាស់ប្រាក់ចំណូលដែលបានមកពីប្រេងសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសេវាសង្គមជាមូលដ្ឋានដូចជា វិស័យអប់រំ និងការគាំពារសុខភាព"។

លោកបានមានប្រសាសន៍ថា "តម្លាភាពនៅក្នុងវិស័យរបស់យើងនឹងជួយធានាថា ប្រាក់ចំណូលត្រូវបានចាត់ចែងក្នុងលក្ខណៈទទួលខុសត្រូវដែលផ្តល់ប្រយោជន៍ដល់ប្រជាជនកម្ពុជាគ្រប់រូប។ ការបង្ហាញពីការបង់ប្រាក់ដោយក្រុមហ៊ុន Chevrin នឹងផ្តល់ព័ត៌មានដ៏មានតម្លៃដល់ក្រុមវិនិយោគិន និងពលរដ្ឋនៅក្នុងប្រទេសដែលសំបូរធនធានដូចជាប្រទេសកម្ពុជាជាដើមដើម្បីកាត់បន្ថយភាពក្រីក្រ និងឱ្យមានកំណើនសេដ្ឋកិច្ច ៕

# សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យទាមទារឱ្យចាត់វិធានការលើមូលនិធិដែលបាត់

ដោយ វណ្ណ អ៊ីន
THE CAMBODIA DAILY

សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យបានឱ្យដឹងកាលពីម្សិលមិញថា ខ្លួនបានសរសេរលិខិតមួយច្បាប់ផ្ញើជូនក្រសួងអប់រំស្នើឱ្យក្រសួងចាត់វិធានការលើនាយិកាស្វាយរៀងដែលសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យអះអាងថា ត្រូវបានស៊ើបអង្កេត ចំពោះការកិបកេងមូលនិធិសាលា ។ លោក រ៉ុង ឈុន ប្រធានសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ បានមានប្រសាសន៍កាលពីខែមេសាថា ក្រសួងបានបញ្ជូនសវនករមួយក្រុមទៅកាន់វិទ្យាល័យ ហ៊ុន សែន ក្រោលគោ នៅក្នុងស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ដើម្បីស៊ើបអង្កេតនាយិកាសាលាឈ្មោះ ទូច សុធា ដែលទោះជាយ៉ាងណារហូតមកដល់ពេលនេះមិនមានការចាត់វិធានការណាមួយលើលោកស្រីនាយិកា ទូច សុធា ទេ។ លោកបានមានប្រសាសន៍ថា "ជាងមួយខែមកហើយ ក្រសួងអប់រំមិនបានចាត់វិធានការដើម្បីដាក់វិន័យ ឬក៏ដាក់ទោសនាយិការូបនេះឡើយ" ។ លោក សី ទីឃាយុ គ្រូបង្រៀនផ្នែកគីមីវិទ្យានៅវិទ្យាល័យនេះ បានមានប្រសាសន៍ថា លោកស្រីនាយិកា ទូច សុធា ត្រូវបានស៊ើបអង្កេតពាក់ព័ន្ធមូលនិធិសាលាដែលមានទឹកប្រាក់ ៤.៨០០ដុល្លារ ដែលត្រូវបានទុកសម្រាប់ប្រើប្រាស់ទិញសម្ភារៈសាលា ដូចជាក្រដាស ការចំណាយផ្នែកថែទាំអនាម័យ និងការចំណាយថ្លៃទឹកភ្លើង ។ លោក សី ទីឃាយុ បានអះអាងថា បើទោះណាវិក្កយបត្រត្រូវបានបញ្ជូនទៅក្រសួងអប់រំសម្រាប់ចំណាយថ្លៃផ្គត់ផ្គង់ និងសម្ភារៈក៏ដោយ ក៏វិទ្យាល័យនេះមិនដែលទទួលបានវិក្កយបត្រដែរ ។ លោកស្រីនាយិកា ទូច សុធា មិនអាចត្រូវបានទាក់ទងសុំការអត្ថាធិប្បាយបានទេកាលពីម្សិលមិញ ចំណែកលោក អ៊ុន ថេរ អ្នកនាំពាក្យក្រសួងអប់រំបានមានប្រសាសន៍ថា លោកមិនបានដឹងអំពីពាក្យបណ្តឹងដែលប្តឹងនាយិការូបនេះទេ ៕

# អាថ៌កំបាំង និងសិល្បៈនៃជីវិត
# SECRET AND ART OF LIVING



**(តមកពីលេខមុន)**

**រៀបរៀងដោយ**
**លោក ម៉ៅ ច័ន្ទសំណុំ**

•••រស់នៅស្ទើរតែក្រៅប្រព័ន្ធម៉េម៉ូរីទាំងស្រុង ពីព្រោះទំហំម៉េម៉ូរីរបស់គេនៅតូចតិច ពុំទាន់មានឥទ្ធិពលមកលើកុមារនៅឡើយ ។ ផ្ទុយទៅវិញ ពេលមនុស្សយើងកាន់តែចាស់ គំនរម៉េម៉ូរីកាន់តែក្រាស់ គរដូចភ្នំ ។ ដោយសារឥទ្ធិពលគំនរម៉េម៉ូរីនេះ មនុស្សចាស់រញ៉ាំញ៉ូវ រអ៊ូរទាំងកើតទុកទោមនស្ស ទោះកូនចៅធ្វើដូចម្ដេចក៏ពុំគាប់ចិត្តឡើយ ។

**ខ. ឥទ្ធិពលសារជាតិគ្រឿងញៀន**

ការសង្កេតសង្គមបានបង្ហាញថា មនុស្សខ្លះបើមានវិបត្តិផ្លូវចិត្តដូចជាកើតទុកព្រាត់សង្សារ ការខាត់បង់ទ្រព្យសម្បត្តិធ្ងន់ធ្ងរដោយប្រការណាមួយ ឈឺចិត្តចាញ់បោកគេ ។ល។ ពួកគេរត់ទៅរកស្រាកញ្ឆា អាភៀន ជួយបំបាត់ទុក្ខ រំងាប់ទុក្ខ ។ តាមពិតសារជាតិគ្រឿងញៀនទាំងនោះ ពេលវាចូលដល់ក្នុងខ្លួនមនុស្ស វាធ្វើសកម្មភាពទប់ស្កាត់លំហូរនៃគំនិតពីបន្ទប់ម៉េម៉ូរីមក។ ពួកគេបានឱកាសរស់នៅក្រៅប្រព័ន្ធម៉េម៉ូរីមួយរយៈតូច ។ ម្លោះហើយអ្នកស្រវឹងស្រា ឬញៀនអាភៀនភ្លេចអស់រឿងរ៉ាវស្មុគស្មាញ ដែលកំពុងកើតមានចំពោះខ្លួន ។ ពេលនោះឯងគេកើតការសប្បាយរីករាយ ហ៊ោកញ្ជ្រៀវ សុខស្រួលក្នុងរាងកាយ ចិត្តពាក្យខ្មែរពោលថា "ស្វាងតឹងស្រវឹងធូរ" ។ ប៉ុន្តែភាពធូរស្រាលនេះ បានតែមួយភ្លែត លុះអស់ជាតិស្រារឿងរ៉ាវចាស់រើឡើងវិញដដែល ហើយសុខភាពត្រូវបាក់ទ្រុឌទ្រោមជាលំដាប់ ។ គួរកុំប្រព្រឹត្តរបៀបនេះ នាំមកនូវគ្រោះថ្នាក់ដល់ជីវិតផ្ទាល់ខ្លួន និងសង្គមផង ។

**គ-ការរួមភេទរវាងបុរសនឹងស្ត្រី**

មាបនកម្ម Creation ឬអ្វីៗដែលកំពុងតែលេចឡើងផុះឡើង កើតឡើងពាសពេញលើភពផែនដីនេះ សុទ្ធតែមានកំណត់ដោយធម្មជាតិ ។

ការភេទរវាងបុរស និងស្ត្រី ក៏ដូចជាការបន្តពូជរបស់សត្វនិងរុក្ខជាតិនានាដែរ សុទ្ធតែជាផែនការ ឬទិសដៅរបស់ធម្មជាតិ (ព្រះអាទិទេព) : ទី១ មនុស្សត្រូវមានបេសកកម្មបន្តពូជមនុស្សតៗគ្នាលើផែនដីនេះ។ ទី២ ធម្មជាតិចង់ប្រាប់ឱ្យដឹងនូវអាថ៌កំបាំងនៃជីវិតមនុស្ស ពោលគឺធម្មជាតិអនុញ្ញាតឱ្យមនុស្សឃើញមួយប៉ព្រិចភ្នែកនូវឋានសួគ៌ (ឬព្រះអាទិទេព) ផុះចេញពីក្នុងខ្លួនឯងគ្រប់ៗគ្នា ពុំលើកលែងនរណាឡើង។ បុរាណតែងប្រើពាក្យក្រេបទឹកឃ្មុំ ឬក្រេបទឹកអមិត ក្នុងពេលរួមភេទនេះ ។ តើមានហេតុភេទអ្វីខ្លះ កើតមាននៅពេលនោះ? តាមពិតពេលដែលមនុស្សពិសោធន៍ការក្រេបទឹកឃ្មុំ the peak of sex experience មនុស្សពិសោធន៍ជីវិតមួយទៀត ដែលឋិតនៅក្រៅឥទ្ធិពលប្រព័ន្ធម៉េម៉ូរី មានន័យថា ចលនាលំហូរនៃគំនិត The flow of thinking or mental activities ត្រូវបញ្ឈប់មួយព្រិប (រំពិចនោះ) មនុស្សពិសោធន៍( ការផុះឡើងដោយឯកឯង spontaneously) ភាពសប្បាយរីករាយឥតគណនា ការសម្រាកដ៏បរិសុទ្ធ សេរីភាពដ៏បរិសុទ្ធ ពន្លឺសុភមង្គល ភ្នែកស្រស់បរមសុខ Bliss នៅពេលដែលមនុស្ស កំពុងរស់នៅក្នុងរូបកាយនេះ ។ ចំណុចកត់សំគាល់មួយចំនួនមានៈ

លោកអ្នកជ្រាបហើយអំពីទំនៀមទំលាប់ក្រេបទឹកឃ្មុំព្រះច័ន្ទ Honey moon នៃគូស្វាមី ភរិយាថ្មី ពោលគឺ គេបង្កលក្ខណៈឱ្យគូស្រករទាំងពីរចាកចេញឆ្ងាយពីជីវិតជាក់ស្ដែង ផុតបញ្ហាស្មុគស្មាញក្នុងជីវិតមួយរយៈបន្ថយការគិតគូរ flow of thinking ទុកឱកាសឱ្យគេទាំងពីរសម្រេចបំណងកាមគុណ ។ ម្យ៉ាងទៀត ក្នុងពេលរួមភេទ បើអ្នកចង់បានសម្រេចដល់គោលដៅ The peak of sex experience អ្នកគួរបញ្ឈប់ចលនាខួរក្បាល ការគិត ការស្រមៃចង់បានដូច្នេះ ឬដូច្នោះ ឬការពាំនាំរឿងរ៉ាវពីកន្លែងធ្វើការទៅលាយឡំឡើយ ពីព្រោះធ្វើយ៉ាងនេះ វាដើរបញ្ច្រាសនឹងដំណើរធម្មជាតិ ។

សមាធិមានឧបករណ៍ ឬមធ្យោបាយជួយឱ្យអ្នកប្រតិបត្តិអាចមានឱកាសស្គាល់រស់ជាតិជីវិត នៅក្រៅប្រព័ន្ធម៉េម៉ូរីបាន ហើយមានពិសោធន៍ភាពស្រណុកសុខសប្បាយបរមសុខបានយូរ ម្ចាស់ការ និងប្រកបដោយជីវិតមានន័យជាងពិសោធន៍ផ្លូវភេទ ។ ពិសោធន៍ផ្លូវភេទបានតែមួយឆាប់ដូចផ្លេកបន្ទោល ហើយធ្វើឱ្យមនុស្សជាប់ស្អិតវង្វេង និងមានផលវិបាកច្រើនបើពុំប្រយ័ត្នទេនោះ ។

ឃ-សមាធិជប៉ុនតាមបែបព្រះពុទ្ធសាសនា "គួន" Koan

សមាធិនេះមានសភាពចម្លែក និងប្រកបដោយអត្ថន័យយ៉ាងជ្រាលជ្រៅ ។ សិស្សដែលចូលហាត់សមាធិនេះ ទទួលសំណួរដ៏ចម្លែកៗពីគ្រូធំ ។ សិស្សម្នាក់ៗមានសំណួរផ្សេងៗគ្នា សំណួរមានដូចជា "បើទះដៃដោយប្រើបាតដៃទាំងពីរ អ្នកនឹងឮស្នូរសម្លេងម្យ៉ាង បើទះដៃដោយប្រើបាតដៃតែមួយ តើអ្នកឮសម្លេងដូចម្ដេច? " ឬសំណួរ "មុនពេលអ្នកកើតពីពោះម៉ែ តើមុខមាត់អ្នកមានទម្រង់ រូបភាពដូចម្ដេច?" ។ល។ សិស្សតម្រូវឱ្យគិតពិចារណាលើសំណួរនោះជាប់រហូត តាំងពីភ្ញាក់ពីដំណេករហូតដល់ចូលដេកវិញ។ រាល់ព្រឹកសិស្សត្រូវជួបគ្រូដើម្បីជម្រាបអំពីការគិតឃើញរបស់ខ្លួន។ ជារឿយៗត្រូវតែបដិសេធថា ពុំត្រូវទេ ចូរបន្តគិតទៅទៀត ។ សិស្សគិតហើយគិតទៀត គិតហើយគិតទៀត សារចុះសារឡើយ។ ស្រាវជ្រាវពីគ្រប់ជ្រុងល្អិតល្អន់ គ្មានចន្លោះត្រង់ណាឡើយ។ ខួរក្បាលរបស់គេ ត្រូវប្រើពេញទំហឹង បើកងស់កុងទ័រ។ ទៅខាងណេះទាល់ទៅខាងណោះទាល់ គ្រូបដិសេធរាល់តែលើក។ សិស្សឋិតក្នុងសភាពទាល់ច្រកជាយូរថ្ងៃ។ ពេលមួយនោះខួរក្បាលហត់ខ្លាំងឡើយៗតឹងឡើងតឹងឡើង តាំងលែងទៅមុខរួច សិស្សត្រូវបង្ខំចិត្តបោះបង់ចោលការប្រឹងប្រែងគិតតទៅទៀត។ រំពិចនោះហើយដែលសិស្សបានរកឃើញពិសោធន៍មួយដ៏អស្ចារ្យ ផុះចេញពីក្នុងមក Spontaneously ពិសោធន៍សន្តិភាពក្នុងចិត្តដ៏ជ្រាលជ្រៅ សប្បាយរីករាយបរមសុខ bliss ក៏រជួបក្នុងជីវិត ។ គ្រូសមាធិទទួលស្គាល់ថា សិស្សនោះទទួលសម្រេចទិសដៅរបស់សមាធិ ហើយតាមពាក្យជប៉ុនគេ ហៅថាសាតូរី ឬការត្រាស់ដឹងភ្លាមៗ (SATORI=Sudden enlightenment) ។ តើហេតុអ្វីក៏បានសម្រេចគោលដៅ? ពីព្រោះសិស្សដែលបោះបង់ការបន្តគិតគូរ សិស្សបានតម្លាក់អាវុធឈប់ច្បាំងតទៅទៀត He surrenders himself in the face war inside រំពិចនោះ ផ្ទៃចិត្តរបស់គេធ្លាក់ទៅក្នុងតំបន់ឈប់គិតទាំងស្រុង មានន័យម្យ៉ាងទៀតថា សិស្សនេះ ជួបនឹងទិដ្ឋភាពជីវិតមួយទៀត ពោលគឺជីវិតក្រៅឥទ្ធិពលប្រព័ន្ធម៉េម៉ូរី ដែលគេពុំដែលពិសោធន៍ពីមុនមកសោះ ។ ដូច្នេះតាំងពីពេលនេះទៅ សិស្សដឹងថា ក្នុងខ្លួនគេមានពីបន្ទប់ទី១ បន្ទប់សម្រាប់គិតគូរពិចារណាធ្វើការងារទី២ បន្ទប់ឈប់គិតទាំងស្រុង ។ បន្ទប់ទី២នេះ គេពុំដែលប្រើទាល់តែសោះពីមុនមកពីព្រោះសង្គមបង្រៀនឱ្យគេហាត់គិតរហូតគេនឹងគិត ។ គេពុំចេះរស់នៅដោយពុំគិតឡើយ នេះជាចំណងរឹតរួតខ្លួនគេជារៀងរហូតមករហូតដល់ស្លាប់ទៅវិញផងក៏ពុំដឹងឡើយ ។ មនុស្សវង្វេងក្នុងរង្វង់ដ៏តូចចង្អៀត (បន្ទប់គិតនេះ Conditioning or un conscious mind) ភាសារសាសនា គេហៅថា វាលវដ្តសង្សារ Samsara ។

ធម្មជាតិបានផ្ដល់សក្ដានុពលពីរយ៉ាងឱ្យមនុស្ស ប៉ុន្តែយើងជាមនុស្សប្រើបានតែមួយចំហៀងប៉ុណ្ណោះ មួយចំហៀងទៀតទុកចោល ទំនេររហូតដល់ស្លាប់ក៏ពុំដឹងឡើយ ។ ពាក្យថាបាតុភូតនេះ ឋិតនៅហួសពីប្រព័ន្ធម៉េម៉ូរី ពីចំណេះដឹងទាំងឡាយ មានតែការពិសោធផ្ទាល់ប៉ុណ្ណោះ ទើបដឹងបាន By intuition ។

សរុបមកវិញមនុស្សពិសោធន៍អាចរស់នៅក្នុងប្រព័ន្ធម៉េម៉ូរី (Waking state and dreaming state) និងអាចរស់នៅក្រៅប្រព័ន្ធម៉េម៉ូរីបាន(deep sleep) ។ ទាំងពីបន្ទប់នេះ សុទ្ធតែមានប្រយោជន៍ទាំងអស់ ។ ជីវិតក្នុងប្រព័ន្ធម៉េម៉ូរី ជួយឱ្យមនុស្សម្នាក់ៗអាចធ្វើការងាររៀនសូត្រ ដោះស្រាយបញ្ហាជីវិតសព្វយ៉ាងនឹងរក្សាជីវិតមនុស្សយើងម្នាក់ៗ ក្នុងលោកសម្ភារៈនេះឱ្យគង់វង់ (The survival in material life) និងរីកចំរើន ។ ប៉ុន្តែនៅទីនេះ មនុស្សរស់នៅដូច តុក្កតាទីងមោងឋិតនៅក្រោម អំណាចរបស់ម៉េម៉ូរី ប្រកបដោយព្យចិត្តបោកបក់ពុំឈប់ឈរឡើយ ។ ជីវិតខាងក្រៅប្រព័ន្ធម៉េម៉ូរី មានសារជាតិស្ងប់ សន្តិភាពរីករាយសម្រាកបរិសុទ្ធ មានសេរីភាព ប្រភពថាមពល ប៉ុន្តែមនុស្សបានឃើញតែមួយឆាបក៏បាត់ទៅ មានអ្នកខ្លះពុំស្គាល់វាតែម្ដង ក្នុងពេលរស់នៅជាមនុស្សនេះ ។ បញ្ហាចោទ គឺថា តើធ្វើយ៉ាងណាឱ្យជីវិតក្រៅម៉េម៉ូរីនេះបានវែង ហើយដើរស៊ីសង្វាក់ Harmony ជាមួយនឹងជីវិតក្នុងម៉េម៉ូរី ? ខ្ញុំនឹងឆ្លើយសំណួរដ៏សំខាន់នេះនៅក្នុងវគ្គក្រោយផ្នែកសិល្បៈនៃជីវិត ។

**ទី៤ កុងស្យនិសបរិសុទ្ធ Pure consciousness (TURIYA)**

ក្នុងខ្លួនយើងម្នាក់ៗមានកុងស្យនិស៤ប្រភេទ ទី១ កុងស្យនិសពេលដឹងខ្លួន wakong state ទី២ កុងស្យនិសពេលយល់សប្តិ Dreaming state និងទី៤កុងស្យនិសបរិសុទ្ធ Pure consciousness ។ កុងស្យនិសទាំងបីខាងដើម ខ្ញុំបានរៀបរាប់អស់ហើយ យើងទាំងអស់គ្នា ក៏សុទ្ធតែបានពិសោធន៍ ។

**(តទៅលេខក្រោយ)**

**New World Travel II**
ញូវើលត្រាវែលធូ

Specialized in Selling Flight Tickets
For National and International

ជំនាញខាងលក់សំបុត្រយន្តហោះសំរាប់ក្នុងប្រទេស និងអន្តរជាតិ យើងតំណាងឱ្យក្រុមហ៊ុន ចិន កូរ៉េ កាថេ ។ល។ ធ្វើលិខិត Re-Entry Permit ប្រញាប់ជូនបានទិញសំបុត្រជិះនាវាសមុទ្រ សណ្ឋាគារ ឬជួលឡាន សំបុត្រយន្តហោះទៅច្រើនប្រទេសក្នុងតម្លៃទាបបំផុត ។

Represented Several of Company such as China, Korea, Cathay etc.,
Offer Rush Re-Entry Permit
Reserve Cruise, Hotels and Car Rentals
Best Price Air Ticket for Many Destinations

600 Washington Ave Suite #8
Philadelphia, Pa 19147
Tel: (215) 463-1257
Fax: (215) 463-2036

លិខិតពីមិត្តអ្នកអាន
លោក អន សុធី
នៅញូជ័រស៊ី 08109

# លោកនាយក សហការខ្មែរប៉ុស្តិ៍ ទាំងអស់ជាទីរាប់អាន

•••ជាបឋម ខ្ញុំសូមថ្លែងនូវអំណរគុណដ៏ជ្រាលជ្រៅបំផុតចំពោះលោកនាយក សហការី-វីរីទាំងអស់នៃខ្មែរប៉ុស្តិ៍ ដែលមានមនសិការជាតិដ៏ឧត្តុង្គឧត្តម បានលះបង់អស់កម្លាំងកាយ-ចិត្តក្នុងការស្រាវជ្រាវរកគ្រប់ព័ត៌មានជាតិ, អន្តរជាតិ មកសរសេរចុះផ្សព្វផ្សាយជូនខេមរជននៅគ្រប់មជ្ឈដ្ឋាន ឱ្យបានយល់ដឹងពីវិវត្តន៍នៃសង្គមជាតិ ទាំងផ្នែកនយោបាយ វប្បធម៌... ពីអតីត និងបច្ចុប្បន្ន ។

ក្រោយពីបានព័ត៌មាន អត្ថបទមួយចំនួនដែលមានខ្លឹមសារមក ខ្ញុំមានសេចក្តីរំភើបរីករាយឥតឧបមា ដោយបានឃើញជនជាតិរបស់ខ្លួន មានគំនិតស្រឡាញ់ជាតិសាសន៍ អ្វីៗជាសារធាតុរបស់ខ្លួន ។

ខ្ញុំមានបំណង សូមស្នើលោកផ្ញើព័ត៌មានខ្មែរប៉ុស្តិ៍ជាប្រចាំឆ្នាំមកខ្ញុំ តាមអាសយដ្ឋានខាងលើ ចាប់ពីថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០១០ នេះតទៅ ។

***ឆ្លើយ*** : *ខ្មែរប៉ុស្តិ៍ សូមអរគុណចំពោះការលើកទឹកចិត្តរបស់លោកអ្នកអាន នេះគឺជាការចូលរួមយ៉ាងសកម្មចំពោះវាស្នាវប្បធម៌ និងទំនាក់ទំនងជាតិយើងជាប្រាកដ ។*

# អាហារជួយកាត់បន្ថយអត្រាប្រឈមនឹងរោគទឹកនោមផ្អែម



•••ពពួកអាហារដែលសំបូរទៅដោយកាកសរសៃទាំងឡាយ ដូចជាអាហារពេលព្រឹក នំប៉័ង ហូលវីដ អង្ករសំរូប ពួកវាអាចជួយទប់ស្កាត់រោគទឹកនោមផ្អែមបាន ។ បើយោងតាមការសិក្សាស្រាវជ្រាវសុខភាពមនុស្សចំនួន២៥.០០០នាក់ អូសបន្លាយពេលអស់៧ឆ្នាំកន្លងមកនេះ គេបានរកឃើញថា អ្នកដែលទទួលទានអាហារសំបូរជាតិកាកសរសៃយ៉ាងហោចណាស់១៧ក្រាមក្នុងមួយថ្ងៃ វាជួយកាត់បន្ថយអត្រាប្រឈមនឹងរោគទឹកនោមផ្អែមបានរហូតដល់២៧ភាគរយ បើប្រៀបធៀបជាមួយនឹងអ្នកបានទទួលទានអាហារប្រភេទនេះត្រឹមតែ៧ក្រាមក្នុងមួយថ្ងៃនោះ ។

មូលហេតុក៏ព្រោះអាហារដែលបណ្តុំទៅដោយជាតិកាកសរសៃ ឬហៅថា ហ្វៃប៊ើរ នោះអាចធ្វើឲ្យកោសិកានៅក្នុងរាងកាយឆាប់ចាប់បានជាមួយនឹងអ៊ីនស៊ុយលីន កាន់តែខ្លាំងឡើងធ្វើឲ្យមិនងាយកើតរោគទឹកនោមផ្អែមនោះឯង ។ ក្នុងមួយថ្ងៃគួរព្យាយាមទទួលទានអាហារជាតិកាកសរសៃនេះឲ្យបាន២៥ក្រាម ដើម្បីសុខភាពកាន់តែល្អឡើង ៕

តមកទំព័រទី ០១

# និស្សិតដែលគេស្តាយនៅពេល...

សិស្សដែលរួសរាយ ចេះជួយយកអាសារអ្នកដទៃ ហើយបានក្លាយទៅជាទីស្រឡាញ់រាប់អាននៃសិស្សរួមថ្នាក់ រួមសាលា ហើយនឹងញាតិមិត្តជុំវិញផ្ទះទៀតផង ។

ម៉ាឌីណា បានគេចផុតពីចរន្តលំបាកវេទនានៃតំបន់ឡូក្លាន់ អលនី ដែលយុវជន យុវនារីខ្មែរដ៏ច្រើន ពុំបានឆ្លងកាត់សិក្សាវិទ្យាល័យរួចទេ រស់នៅជុំវិញគ្រួសារក្រីក្រ ហើយមានអបាយមុខគ្រប់យ៉ាងទៀតផង ដោយនៅចុងបញ្ចប់នៃថ្នាក់ទី១២នេះ នាងបានទទួលការកោតសរសើរយ៉ាងកក់ក្តៅ និងច្បាស់លាស់ពីនាយកវិទ្យាល័យ នាងដឹកមុខការងារសិក្សាយ៉ាងរីករាយជាសញ្ញានៃពន្លឺអនាគតប្រសើរយ៉ាងគួរឱ្យកត់សំគាល់ ។






បុណ្យសពរបស់នាង នៅ"ម៉ាន់ ហ្វូណេ-រាល់ហូម" បានត្រូវមិត្តភ័ក្រភូមិផង និងសាលារៀនបានរៃអង្គាស - លក់របស់របរ - ធ្វើនំលក់...។ល។ ហើយយកប្រាក់នោះមកឱ្យគ្រួសារ ម៉ាឌីណា ទាំងអស់។

នៅរាត្រីថ្ងៃពុធ ដែលមិត្តភ័ក្រ និងគ្រួសារដ៏កកកុញមកចូលរួមពិធីដុតទៀនរំលឹកវិញ្ញាណក្ខន្ធទៅទីដែលគ្រោះថ្នាក់បានកើតឡើង និងទីដែលរូបថតមួយផ្ទាំងរបស់ ម៉ាឌីណា បានព្យួរនៅទីនោះ... ម៉ាឌីណា បើនៅរស់អាចឃើញមិត្តភ័ក្របានស្រក់ទឹកភ្នែក ដើម្បីនាងបាននិយាយរំលឹកពីគុណសម្បត្តិរបស់នាង សំ ប៊ិន, មេលីណា, ជាបងស្រីឆ្លើយនឹងសំនួរខ្លះៗ ដោយសម្លេងញាប់ញ័រទាំងទឹកភ្នែកហូរមិនឈប់... មានសិស្សខ្លះបាននិយាយថា ម៉ាឌីណា ធ្លាប់បានជួយជីវិតគេ ដោយណែនាំមិនឱ្យសម្លាប់ខ្លួនឯងបានទៀតផង ។

រថយន្តដែលបានបុក ម៉ាឌីណា គឺបានខ្ទាតពីការប៉ះទង្គិចគ្នានៅផ្លូវខ្វែង បណ្តាលឱ្យលើចិញ្ចើមថ្នល់មកបុក ម៉ាឌីណា ប៉ូលិសបានប្រាប់កាសែតថា "នៅមានការអង្កេតជាបន្ត ប៉ុន្តែឥតបានចេញប័ណ្ណផាកពិន័យទេ" ហើយម្ចាស់រថយន្តនោះក៏ទៅព្យាបាលរបួសរបស់ខ្លួននៅពេទ្យអាញស្តាយដែរ ៕

From :Philadelphia


សួស្តីឆ្នាំថ្មី
ហាងខ្មែរជួសជុលរថយន្ត
បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ

**Rathe`s Auto Service**




State and Emission
Inspection General
Repairs and Maintenance

MON-SAT, 8:30AM -5:30PM
SUN. EMERGENCY ONLY

-ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
-មានដូរប្រេង ដូរប្រាំង ដូរកង់ និងករណីជាច្រើនទៀត ។
-មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ -មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨ ទៅ : -ដូរប្រេងកឺរត ៥ ក្វាត $22. - INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ពាក់-មានជូនប័ណ្ណពិសេស សំរាប់ដូរប្រេង ចុះថ្លៃពាក់កណ្តាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
-តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត
- ប្តេជ្ញាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ ។
ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអរគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL: (215) 329-2418
Fax: (215) 329-2419.Rath CELL: (215) 431-6376

Yes you can!

... get free or low-cost health insurance for your children.

- Did you lose your health insurance when you lost your job?
- Do your children have no health insurance?
- Do you wonder how you'll afford your kids' next doctor visit?

AmeriChoice
A UnitedHealth Group Company

(215) 360-9841
Leap Thach

Your children deserve to be healthy.
AmeriChoice can help.



## តមកទំព័រទី ០៣ សម រង្ស៊ី ចោទគណបក្សប្រជាជនថាជា...

មានចេតនាមិនចង់ច្របាច់រួមជាមួយនឹងគណបក្សសិទ្ធិមនុស្សឡើយ ប៉ុន្តែបែរជាមានចេតនាចង់រួមជាមួយគណបក្សហ៊្វុនស៊ិនប៉ិច ពីព្រោះលោក ញឹក ប៊ុនឆៃ ជាមនុស្សអាចទៅនិយាយជាមួយនឹងលោក ហ៊ុន សែន ដើម្បីឱ្យលោក សម រង្ស៊ី អាចវិលចូលស្រុកវិញ បានដោយគ្មានទោសពៃរ៍ តើឯកឧត្តមមានការបកស្រាយយ៉ាងណាដែរចំពោះបញ្ហាទាំងហ្នឹង?"។ គ្មានការបកស្រាយឱ្យបានតែលោក សម រង្ស៊ី ខ្លួនឯងម្នាក់ប៉ុណ្ណោះ ទើបដឹងច្បាស់អំពីអាថិកំបាំងនយោបាយដ៏សែនស្មុគស្មាញ និងគ្រោះថ្នាក់បំផុតនេះ ។ ប៉ុន្តែគេក៏មិនប្រាកដដែរថា គណបក្ស សម រង្ស៊ី ក៏អាចនឹងច្របាច់រួមគ្នាជាមួយបក្សសិទ្ធិមនុស្សសម្រាប់យកជ័យជំនះលើការបោះឆ្នោតជាសកលមួយនៅឆ្នាំ២០១៣ខាងមុខនេះ....។

នៅមានសំណុំរឿងថ្មីដោយឡែកផ្សេងមួយទៀត





តំណាងរាស្ត្រខ្មែរពីររូប គឺ ជូឡុង សូមូរា និងលោក សម រង្ស៊ី

ចួយជុំវិញសំនួរខាងលើឡើយ ប៉ុន្តែ លោក រង្ស៊ី ក៏បានបញ្ជាក់អំពីជំហររបស់ខ្លួនថា ពុំមានថ្ងៃប្រែប្រួលឡើយ ។ លោកបញ្ជាក់ថា "ចំពោះគណបក្សនេះ បក្សនោះ បុគ្គលនេះ បុគ្គលនោះគ្មានអ្វីសំខាន់ឡើយ ប៉ុន្តែកត្តាសំខាន់នោះ គឺជំហរឱ្យ តែបក្សណា បុគ្គលណាមានជំហរច្បាស់លាស់ គឺយើងរួបរួមគ្នាបាន..."។

ក៏ប៉ុន្តែកូនក្តីសង្ស័យតូចមួយ ត្រូវបានកើតឡើងចំពោះអ្នកស្នេហាប្រជាធិបតេយ្យនៅពេលដែលបានឮការសន្យារបស់លោក សម រង្ស៊ី នារាត្រីថ្ងៃទី២៣នោះថា "នៅពេលបោះឆ្នោតនៅឆ្នាំ២០១៣ ខាងមុខនេះ គណបក្ស សម រង្ស៊ី នឹងរួបរួមជាមួយបក្សមួយទៀតឱ្យក្លាយជាបក្សតែមួយ..."។ លោក រង្ស៊ី ពុំបានបញ្ជាក់អំពីឈ្មោះគណបក្សដែលត្រូវជាថ្ងៃគូស្លាប់រស់នោះឡើយ ហើយប្រការនេះឯងកាន់តែញ៉ាំងឱ្យមានការសង្ស័យ ងឿងឆ្ងល់យ៉ាងខ្លាំងពីមជ្ឈដ្ឋានមហាជនយ៉ាងខ្លាំងថា តើគណបក្សណានឹងភ័ព្វអាចរួមជាមួយគណបក្ស សម រង្ស៊ី នោះ? តើជាគណបក្សសិទ្ធមនុស្ស? គណបក្សហ៊្វុនស៊ិនប៉ិច? ឬមួយគណបក្សប្រជាជនកម្ពុជា?

គេពុំបានធ្វើការសន្និដ្ឋានវាយតម្លៃពាសវាលពាសកាល ដោយគ្មានប្រភពច្បាស់លាស់បានឡើយ គឺមានដែលគណបក្ស សម រង្ស៊ី ហាក់មិនសប្បាយចិត្តសោះឡើយចំពោះការបោះបង្គោលព្រំដែនលេខ ២៧០ ដែលគណៈកម្មាធិការព្រំដែនកម្ពុជា-យួន កំពុងសាងសង់នាពេលនេះ ។ បក្សជំទាស់របស់លោក រង្ស៊ី បានស្រែកថា : "ការបោះបង្គោលព្រំដែនលេខ ២៧០នេះ បានធ្វើឱ្យបាត់បង់ដីស្រែរាប់សិបហិចតារបស់ប្រជាកសិករខ្មែរ ព្រោះបង្គោលនោះស្ថិតនៅលើដីកសិករខ្មែរ..."។ ជាក់ស្តែងប្រជាកសិករខ្មែរ ដែលស្ថិតនៅក្នុងភូមិអញ្ចាញ ឃុំជ័យជោត ស្រុកបូរីជលសារ ក្នុងខេត្តតាកែវ ក៏ធ្លាប់បានតវ៉ាម្តងរួចមកហើយចំពោះការបោះបង្គោលព្រំដែនលេខ ២៧០នេះ ប៉ុន្តែនៅពុំទាន់មានដំណោះស្រាយសម្រាប់ពួកគាត់នៅឡើយ ។

ក្នុងលិខិតមួយផ្ញើរជូនទៅលោក ហ៊ុន សែន តាមរយៈលោក ហេង សំរិន ប្រធានរដ្ឋសភា, តំណាងរាស្ត្រនៃគណបក្សប្រឆាំង សម រង្ស៊ី បានឯកភាពដោយមានស្នាមមេដៃផងនោះ បានសរសេរជាពាក្យមួយឃ្លាថា "ការបោះបង្គោលព្រំដែនលេខ ២៧០ ដូចមានកំណត់ក្នុងផែនទីផ្លូវការឆ្នាំ ១៩៥២ មាត្រដ្ឋាន ១/១០០.០០០ ដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិនៅចន្លោះឆ្នាំ ១៩៦៣-១៩៦៩ នោះឡើយ"៕

## លីផែនទីដើររកការពិត



**ដោយ : រស់ យ៉ឹន**

•••មានពាក្យបូរាណថា **"ចិនលីគម្ពីរដើររកអ្នកមានបុណ្យ"** ដល់មកដើមសតវត្សរ៍ទី២១ ស្រាប់តែមានតួអង្គមេបក្សប្រឆាំង **"លីផែនទីដើររកការពិត"** ទៅវិញ។ ព្រោះហេតុអ្វីទៅ ?

ក្នុងទសវត្សរ៍ឆ្នាំ ៧០-៨០ សាសន៍ចិនបានលីគម្ពីររកឃើញ**អ្នកមានបុណ្យ**នៅស្រុកខ្មែរ ។ ក្នុងការរុករកអ្នកមានបុណ្យនោះ សាសន៍ចិនត្រូវប្រើមនោគមន៍វិជ្ជាកុម្មុយនិស្ត ដែលជាបុព្វហេតុធ្វើជាតិខ្មែរស្លាប់អស់បីលាននាក់ ។ ក្រុមអ្នកបើកសារណាប្រយុទ្ធនោះ គឺខ្មែរក្រហមក្រោមបញ្ជារបស់សម្តេចឪ ។ សព្វថ្ងៃចិនចាប់បានអ្នកមានបុណ្យនោះទៅតម្កល់ទុកក្នុងសារមន្ទីររបស់គេនៅឯក្រុងប៉េកាំងដ៏សែនមហាសុខសាន្ត ។ ប៉ុន្តែគេមិនភ្លេចសោះឡើយថា អ្នកមានបុណ្យអង្គនោះ ធ្លាប់បានធ្វើទុក្ខបុកម្នេញនិរទេសក្រុមគ្រួសារមេបក្សប្រឆាំងចេញពីនគរខ្មែរ ។ ឪពុកលោកមេបក្សប្រឆាំងបាត់ខ្លួនយ៉ាងអណោចអធម្មក្នុងឆ្នាំ ១៩៥៨ ។ ចុះកម្មអ្វីអាក្រក់ម្លេះ ?

ហាសិបប្រាំបី (៥៨) ឆ្នាំកន្លងមកបុត្ររបស់អ្នករងគ្រោះ ដែលធ្វើមេបក្សប្រឆាំងសព្វថ្ងៃនេះត្រូវតុលាការកាត់ទោសពីបទដកបង្គោលព្រំដែននៅខេត្តស្វាយរៀង ជាខេត្តអនុស្សាវរីយ៍ដែលម្តាយគាត់ដឹកដៃឆ្លងកាត់ទៅស្រុកយួន នៅពេលដែលរដ្ឋាភិបាលសង្គមរាស្ត្រនិយមនិរទេសចេញពីស្រុកខ្មែរ ។

ការបន្ទោកបន្ទាប គួររូបផ្តែ ក្បាលជាមនុស្សជា ឪពុកមេបក្សប្រឆាំងសម័យនោះ គ្មានវរៈជនណាឬសភា ជាតិហ៊ានធ្វើការប្រឆាំងទាល់តែសោះ ។ ប្រជាជនខ្មែរ ក៏ត្រូវបាត់មាត់ឈឹង!!! ពីកាលនោះមកសព្វថ្ងៃនេះ ព្រឹត្តិការណ៍នយោបាយខ្មែរខុសគ្នាស្រឡះដូចមេឃ និងដី ។ ស្ថានភាពនយោបាយរបស់លោកមេបក្សប្រឆាំងមានលក្ខណៈជាសកលមានប្រជាជនគាំទ្ររាប់លាននាក់ ធ្វើការបោះឆ្នោតតាមរបបនយោបាយសេរីពហុបក្ស បានទទួលលទ្ធផលគួរឱ្យចាប់អារម្មណ៍។ មានតំណាងរាស្ត្រក្នុងមន្ទីរសភាជាតិចំនួន២៦នាក់ ដែលពលរដ្ឋបានបោះឆ្នោតជូនក្នុងឆ្នាំ ២០០៨ អាណត្តិទី៤ មិនដូចគ្នានឹងឪពុកគាត់ ដែលគ្រាន់តែជាបុរសរដ្ឋម្នាក់ដ៏កសត់ ប៉ុណ្ណោះទេ ។

បុព្វហេតុព្រំដែនខ្មែរ-វៀតណាមនោះហើយ ដែលលោកមេបក្សប្រឆាំងបានក្លាយខ្លួនជាអ្នកមានឥទ្ធិពលអាច**ថ្លែងសារ**សំដៅទម្លុះបំបែកយុទ្ធសាស្ត្រសហព័ន្ធឥណ្ឌូចិន ដែលប៉ុនប៉ងលេបត្របាក់កម្ពុជា។ លោកមេបក្សប្រឆាំងកំពុងតែ**លីផែនទីខ្មែរដើររកការពិត** ជាគំនិតវិជ្ជមាន ។ ខុសគ្នានឹងចិនលីគម្ពីរដើររក**ព្រះបាទធម្មិក** ជាយុទ្ធនាការណ៍ប្រជាភិថុតសាបព្រួសទ្រឹស្តីទ្រង់ទ្រាយធំ មានគ្រោះថ្នាក់វិនាសកម្មដល់មាតុភូមិខ្មែរ រហូតសព្វថ្ងៃ ។ ចិនសង្កត់យួន-យួនជាន់កខ្មែរ-ជម្រុញខ្មែរឱ្យរុលទៅទិសខាងលិចបន្តិចម្តងៗ សង្គ្រាមការទូតកាន់តែបរាជ័យ កម្លាំងប្រដាប់អាវុធកាន់តែចាស់ជរា។ ឱកាសកសាងសេដ្ឋកិច្ចក៏របូតបាត់ពីដៃខ្មែរ វិស័យដូចក្តាប់ដីខ្សាច់ដើរបង់បោយ ។ យូរបន្តិចទៅតើដីខ្សាច់នោះសល់ប៉ុន្មានគ្រាប់នៅក្នុងដីខ្មែរ ? បានសេចក្តីថា ខ្មែរនឹងក្លាយជាជនភាពតិចរស់នៅក្នុងទឹកដីដូនតារបស់ខ្លួនដូចខ្មែរក្រោម ។ សម្បត្តិដ៏មហាសាលចេះតែផុះ-ខ្មែរ ចេះត្រឹមតែឈ្លោះប្រកាន់ពូកបក្ស សីលធម៌ក៏ធ្លាក់ចូលក្នុងអន្ទាក់យួនកាន់តែជ្រៅ ។ មានពាក្យសុភាសិតខ្មែរពោលទុកថា : អំពៅទោះបីនៅក្នុងឃ្នាប គង់រក្សាភាពផ្អែមជានិច្ច **ជាតិខ្មែរ** ទោះធ្លាក់ក្នុងជ្រោះជ្រៅដូចម្តេចក៏មិនភ្លេចការតស៊ូ ។

អូ ! កុំសាំញ៉ាំពេក នេះគ្រាន់តែជាសោត្តវិស័យនៃមនុស្សម្នាក់ទេ... នរណាធ្វើអីក៏ធ្វើទៅ... ឱ្យតែជាតិយើងរស់ ៕




# ឱសថស្ថាន ខ្មែរថ្ងៃនេះ

TANG PHAMACY

FREE DELIVERY Locally

ចាំងឱសថស្ថាន សូមស្វាគមន៍

ឱសថស្ថានយើងមានទទួលយក Medicare, Medicaid និង Insurance **គ្រោះថ្នាក់ចរាចរ និងគ្រោះថ្នាក់នៅកន្លែងធ្វើការ**នានា ។ លោកប្រុស និងអ្នកស្រី អាចទាក់ទងជាភាសាខ្មែរ ដោយកញ្ញា គីម ជូលី (បន្ទាប់ពីម៉ោង១រសៀល)

| ថាំង ទទួលវេជ្ជបញ្ជា បន្ទូតម្លៃបណ្ណ ចំពោះថ្នាំ (Generic Drug) | តម្លៃ $6.00 ចំពោះថ្នាំសំរាប់ ប្រើចំនួន ៣០ ថ្ងៃ | យើងមានថ្នាំចំនួន 1500 មុខ ដែលមានគុណភាព ប្រសើរ ដូចថ្នាំមានឈ្មោះល្បី (Generic Drugs) |
|---|---|---|


JULIE KIM, MANAGER
(Khmer Contact After 1 pm)

សូមទាក់ទងហាងថ្នាំយើងខ្ញុំនៅអាស័យដ្ឋាន និងទូរស័ព្ទខាងក្រោម បើលោកអ្នកនៅមានចម្ងល់អ្វីមួយ ។



Open : mon-Fri.9a.m-5p.m
5600 North. 5th Street.
Philadelphia, PA 19120
Tel: (215) 224-3333 Fax: (215) 224-3363


តមកទំព័រទី ០១

# អណ្តូងរ៉ែមាសនៅកម្ពុជា...





លោក ឌូក្លាស ប្រូឌ្រីក តំណាងឱ្យអង្គការសហប្រជាជាតិក្នុងកម្មវិធីអភិវឌ្ឍន៍នៅកម្ពុជា បានថ្លែងនៅក្នុងសន្និសីទនៃក្រសួងឧស្សាហកម្មថា "វិស័យអណ្តូងរ៉ែនៅកម្ពុជា កំពុងតែបន្តអភិវឌ្ឍន៍ ក៏ប៉ុន្តែយើងចង់ឃើញសន្និសីទនៃក្រសួងអណ្តូងរ៉ែនេះ និងលើកទឹកចិត្តដល់អ្នកវិនិយោគ..." ។

ក្រុមអ្នកជំនាញការណ៍ខ្មែរខាងកិច្ចការស្រាវជ្រាវធនធានក្រោមដីកម្ពុជា ធ្វើការជិតដិតជាមួយលោក ស៊ាន ប៉េងសែ ប្រធានគណៈកម្មាធិការព្រំដែនកម្ពុជា ដែលមានឈ្មោះថា ស៊ីស៊ីវី (CCV) ធ្លាប់បានធ្វើការផ្សព្វផ្សាយតាំងពី១៥ឆ្នាំមកហើយ នូវនិក្ខេបបទរបស់ខ្លួន ស្តីពីអណ្តូងរ៉ែមាសនៅកម្ពុជាថា "រ៉ែ មាសនៅកម្ពុជា មានចាប់ពីរតនគិរី កាត់តាមកំពង់ធំ រហូតដល់សៀមរាប តែក្នុងចំនួនតិចតួចជាច្រើនកន្លែង..." ។

រីឯអង្គការ គ្លោបូល វិតណេស (Global Withness) ដែលឃ្លាំមើលកម្ពុជា ពីទីស្នាក់ការខ្លួននៅទីក្រុង ឡុងដុន បាននិយាយថា "កម្ពុជាមានប្រាក់ចំណូលពីធនធានធម្មជាតិច្រើនរាប់ទាំងអណ្តូងរ៉ែផង តែធនធាននេះបានត្រូវពង្វាង ដោយអំពើក្រខ្វក់ពីថ្នាក់ដឹកនាំ - ពីការនិយមគ្រួសារ និងពីការរំលោភ" ក្រុមនេះបន្តថា "កម្ពុជាមានធនធានគ្រប់គ្រាន់ហើយ សម្រាប់ចិញ្ចឹមខ្លួនឯង ដោយមិនចាំបាច់ជំនួយពីពិភពលោក ដូច្នេះ ម្ចាស់ជំនួយគួរបង្កើនការតាមដានរបស់ខ្លួន ដើម្បីធានាថា ប្រាក់របស់ខ្លួននឹងយកទៅគ្រប់គ្រងបានត្រឹមត្រូវ" ៕


មានជំនាញខាងទិញ.លក់ផ្ទះ.ពាណិជ្ជកម្ម. វិនិយោគ ហិរញ្ញវត្ថុ ឬជួល
យើងសូមគោរពអ្នកទាំងអស់គ្នា វិនិយោគ



Vinh Ho, 215-391-9516
Email: vho.realestate@consultant.com
ANCHOR Real Estate Development
320 Oregon Ave, #3B, Philadelphia, PA 19148
Specialize - Buy_Sell_Invest_Finance_Rent ...
Beginner-investors are welcomed!

Repro Center
怡保印刷中心
the printer you can trust
Since 1993

- Fast, Easy Print Ordering
- Premium Quality
- Low Price
- Excellent Customer Service

T: 215.271.5041 /5042
1531-33 South 7th Street
Philadelphia • PA 19147
F.: 215.271.5043 • reprocenter@usa.net

BUSINESS CARDS as low as $15



## សេវាបោះពុម្ព

- តារាងម្ហូបភោជនីយដ្ឋាន
- លិខិតចម្លងគ្មានកាបូន
- កែអស័យដ្ឋាន
- ស្រោមសំបុត្រ
- ថតចម្លងពណ៌ឌីស៊ីតុល
- សេវាបញ្ញូនលិខិត
- កាតាឡុកសៀវភៅ
- ខិតប័ណ្ណបត់ជាសៀវភៅ
- ខិតប័ណ្ណលាត
- រូបផ្ទាំងស្អាតតូចៗ
- ផ្ទាំងរូបផ្ទាំងស្អាតធំៗ
- ប្រតិទិន
- ធ្វើហ្វូលឌ័រសម្រាប់ផ្សាយ
- បកប្រែ
- គូសក្រាហ្វិក
- ធ្វើត្រាមាស
- អុតលើក្រប
- ធ្វើក្រប
- ប្រតិទិន
- ដាក់លើក្រណាត់ ឬសូត្រ

Services Products

- Restaurant Menu
- Carbonless NCR Form
- Business Cards
- Envelopes
- Letterhead
- Digital Color Copy
- Mailing Services
- Catalogs / Booklets
- Brochures
- Flyers
- Postcards
- Posters
- Calendars
- Presentation Folder
- Translation
- Graphic Design
- Gold Foil Stamping
- Laminating
- Labels
- Clothing Embroidery / Silk Screen

Danny's Café



Foods & Hoagies

1. Beef Stew Serve with Bread.....................នំប៉័ងខគោ
2. Curry Chicken Serve with Bread.............នំប៉័ងការីសាច់មាន់
3. Curry Beef Saramann Serve with Bread....នំប៉័ងសាច់គោ ខការីសារ៉ាម៉ាន់
4. Meatball Soup Serve with Bread ............ស៊ុបប្រហិតជាមួយនំប៉័ង
5. Mi Siam .............................................មីសៀម





1730 Snyder Ave, Philadelphia, PA 19145 / Mon – Fri: 7am – 7pm Saturday: 9 am – 8 pm / Sunday : CLOSED
Tel: 215.467.4082 Fax: 215.467.4642 / Thank You, Please come again !


Totally Traditional!
Totally Cambodielicious!
ទាបំពងទឹកត្រីអំពិលទុំ
KAVEI CAMBODIAN RESTAURANT
Authentic Khmer • Thai • Lao • Vietnamese Phở
320 W OREGON AVENUE
(OREGON MARKET, SOUTH PHILLY)
215.952.6688
OPEN 7 DAYS A WEEK
9am-10pm